ភ្នំម៉ាឡៃ ៧/០០

# សួង ស៊ីគឿន

# ជាមួយ

# អៀង សារី និង អៀង ធីរិទ្ធ

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
....../....../......
ម៉ោង (Time/Heure): 09-Aug-2010, 14:20
Chanthan Phok

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ បញ្ជាក់ (Certified Date /Date de certification):
09-Aug-2010, 14:20
Chanthan Phok

## V- ជាមួយអ្នកស្រី អៀង ធីរិទ្ធ នៅទីក្រុងហាណូយ

### ១- អ្នកទទួលខុសត្រូវសារប័ត្រអន្តរជាតិនៃវិទ្យុ “សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា” (FUNK)

### ការចេញដំណើរ

នៅទីបំផុត ថ្ងៃដែលរង់ចាំអស់រយៈពេលជាយូរមកហើយនោះក៏បានមកដល់។ លោក អៀង សារី ខ្លួនឯងផ្ទាល់ជាអ្នកប្រាប់ដំណឹងនេះដល់ខ្ញុំ នៅចំពោះមុខលោក ខៀវ សំផន។ យន្តហោះពិសេសរបស់ចិន ដែលបានដឹកពួកយើងក្នុងអំឡុងពេលពួកយើងធ្វើទស្សនកិច្ចរយៈពេលមួយខែ (ពីដើមខែមេសា រហូតដល់ដើមខែឧសភា ឆ្នាំ១៩៧៤) ទៅកាន់ប្រទេសអាហ្វ្រិចចំនួន ១១ បានហោះចូលជិតដល់អាកាសយានដ្ឋានក្រុងប៉េកាំង។ ខ្ញុំមានសេចក្តីរំភើបរីករាយយ៉ាងខ្លាំង ដោយសារខ្ញុំមានបំណងចង់ចូលរួមតស៊ូក្នុងប្រទេសតាំងពីយូរណាស់មកហើយ។ ដើម្បីកិត្តិយសដ៏មហាឧត្តុង្គឧត្តមនេះ ខ្ញុំបានបដិសេធមិនទទួលយកតំណែងជាឯកអគ្គរាជទូតប្រចាំនៅប្រទេសគុយបា និងប្រទេសឈីលី ដែលលោក សារិន ឆាក កាលនោះជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK) បានស្នើប្រគល់ដល់រូបខ្ញុំ។ ខ្ញុំក៏បានត្រៀមខ្លួនបែកគ្នាពីភរិយារបស់ខ្ញុំ និងកូនស្រីទាំងពីរឈ្មោះ ណារ៉ែន និងសុខា ដោយគ្មានពេលវេលាកំណត់។ ប៉ុន្តែពលិកម្មមានតម្លៃធំធេងណាស់ ពីព្រោះថាការចូលរួមក្នុងតំបន់រំដោះ នៅខណៈដែលភ្លើងសង្គ្រាមកំពុងឆេះសន្ធោសន្ធៅពោរពេញទៅដោយគ្រោះថ្នាក់ និងភាពខ្វះខាតសព្វបែបយ៉ាង គឺជាការបង្ហាញនូវការផ្សារភ្ជាប់ខ្លួនរបស់បញ្ញវន្តស្នេហាជាតិមាតុភូមិទៅនឹងបុព្វហេតុជាតិ ដោយមិនអាចប្រកែកបាន។

ការចេញដំណើររបស់ពួកយើងត្រូវបានកំណត់យកថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៤ ដែលជាថ្ងៃខួបកំណើតគម្រប់អាយុ២៧ឆ្នាំរបស់ភរិយាខ្ញុំឈ្មោះ ឡូរ៉ង់ ពិច (Laurence Picq)។ កូនស្រីទាំងពីររបស់ខ្ញុំ ក្នុងសម្លៀកបំពាក់ខ្មៅ បានមកជូនដំណើរខ្ញុំនៅអាកាសយានដ្ឋានជាមួយម្តាយរបស់ពួកគេ។ ទោះបីជាពួកគេបានបញ្ចេញស្នាមញញឹម និងទឹកមុខគ្មានកង្វល់ក៏ដោយ ក៏ខ្ញុំមិនអាចទប់ចិត្តមិនឲ្យពើតផ្សាបានដែរ។ ប៉ុន្តែវត្តមាននៃមិត្តភក្តិជាច្រើនបានធ្វើឱ្យខ្ញុំធូរស្រាលក្នុងចិត្តឡើងវិញ។ ភរិយាខ្ញុំក្នុងសម្លៀកបំពាក់ខ្មៅដែរ ហាក់ដូចជាមានទុក្ខព្រួយ និងស្ងៀមស្ងាត់ខុសពីធម្មតា។ ថ្វីត្បិតតែនាងបានយល់ព្រមឱ្យខ្ញុំចាកចេញ ប៉ុន្តែនាងនៅតែមិនច្បាស់ចំពោះអនាគតនោះឡើយ ព្រោះថា “ចាកចេញ គឺមានន័យថា ស្លាប់បន្តិចទៅហើយ”។

នៅពេលព្រឹកមួយពោរពេញដោយពន្លឺព្រះអាទិត្យ ខ្ញុំបានចាកចេញពីអាកាសយានដ្ឋានអន្តរជាតិក្រុងប៉េកាំងជាមួយ ទន់ ជោតស៊ីរិន ដែលជាមិត្តម្នាក់របស់ខ្ញុំនៅក្នុង "ក្រុមម៉ាក្សលេនីននិយម" នាក្រុងប៉ារីស។ គាត់គឺជាជីវវិទូម្នាក់ដែលនឹងមានអនាគតភ្លឺស្វាង តែបានផ្អាកការស្រាវជ្រាវរបស់គាត់នៅមជ្ឈមណ្ឌលពិសោធន៍អ័រសៃ (Orsay) ដើម្បីទៅចូលរួមក្នុងតំបន់រំដោះនៃប្រទេសកម្ពុជា។ គាត់បានទុកចោលនៅទីក្រុងប៉េកាំងនូវ កូនប្រុសទាំងពីរ និងភរិយាវ័យក្មេងរបស់គាត់ឈ្មោះ វីផា ដែលជាប្អូនស្រីរបស់លោក ផ្អែក ឆាត ជាវិស្វករទីមួយផ្នែកស្ពានថ្នល់នៃប្រទេសកម្ពុជា។

ពីរថ្ងៃមុនពេលខ្ញុំចេញដំណើរ ការិយាល័យរបស់រណសិរ្សរួបរួមជាតិកម្ពុជាប្រចាំនៅទីក្រុងប៉េកាំងបានរៀបចំពិធីជួបជុំលាគ្នាមួយ ជាកិត្តិយសដល់ពួកយើង។ បទអន្តរាគមន៍ដ៏គួរឱ្យកត់សម្គាល់មួយត្រូវបានថ្លែងដោយព្រះអង្គម្ចាស់ក្សត្រីខ្សែស៊ីសុវត្ថិមួយអង្គត្រូវជាព្រះភាគិនេយ្យារបស់ព្រះអង្គម្ចាស់យុត្តិវង្ស ជាព្រះស្ថាបនិកបក្សប្រជាធិបតេយ្យ។ វាគ្មិនទាំងអស់បានលើកសរសើរអំពីស្មារតីពលិកម្ម និងសេចក្តីក្លាហានរបស់មិត្តនារីផល (ឡូរ៉ង់ ពិច) ជាភរិយារបស់ខ្ញុំ។ ចំណែកឯកូនស្រីទាំងពីររបស់ខ្ញុំក៏ទទួលបាននូវការកោតសរសើរផងដែរ។

ខ្ញុំ និងស៊ីរិន បានធ្វើដំណើរជាមួយលោក អៀង សារី លោក ខៀវ សំផន និងអ្នកស្រី អៀង ធីរិទ្ធ តាមជើងយន្តហោះពិសេសរបស់ចិន ដែលបានចុះចតនៅទីក្រុងហាណូយនៅប្រហែលជាថ្ងៃត្រង់ បន្ទាប់ពីហោះហើរអស់រយៈពេលមួយម៉ោងពីទីក្រុងប៉េកាំងមក។

ទីក្រុងហាណូយមិនមែនថ្មីថ្មោងសម្រាប់ខ្ញុំនោះទេ។ ខ្ញុំធ្លាប់បានធ្វើទស្សនកិច្ចនៅទីក្រុងនោះកាលពីបួនឆ្នាំមុន។ ពេលនោះ ខ្ញុំជាសមាជិកគណៈប្រតិភូនៃ FUNK និង GRUNK ដែលដឹកនាំផ្ទាល់ដោយសម្តេច នរោត្តម សីហនុ។ ហាណូយរក្សានូវទិដ្ឋភាពជាទីក្រុងអាណានិគមចំណាស់ ដែលនៅមានបន្សល់ទុកនូវស្លាកស្នាមនៃសង្គ្រាមអាកាសអាមេរិក ជាមួយនឹងគំនរបាក់បែកនៃអគារដែលបំផ្លាញដោយការទម្លាក់គ្រាប់បែក។ នៅក្នុងក្រសែភ្នែករបស់ខ្ញុំ ទីក្រុងនេះតំណាងឱ្យការតស៊ូប្រកបដោយវីរភាព ទប់ទល់នឹងការឈ្លានពានរបស់ពួកបរទេស និងមោទនភាពមិនអាចបង្ក្រាបបានរបស់ប្រជាជាតិតូចមួយ ទល់នឹងឆន្ទៈអនុត្តរភាពនិយមរបស់ប្រទេសមហាអំណាចមួយ។ ប៉ុន្តែការរស់នៅទីក្រុងហាណូយមិនមែនជារឿងងាយស្រួលនោះទេ។ អាកាសធាតុត្រជាក់ខ្លាំងនៅរដូវរងារ និងក្តៅខ្លាំង នៅរដូវក្តៅ ហើយមានសំណើមរហូត ធ្វើឱ្យខ្ញុំស្ទើរតែមិនអាចទ្រាំទ្របាន។

នៅប្រហែលថ្ងៃត្រង់ យន្តហោះដែលពួកយើងជិះបានចុះចតនៅអាកាសយានដ្ឋានក្រុងហាណូយ។ គេបាននាំពួកយើងទៅកាន់សណ្ឋាគាររៀវរដ្ឋាភិបាល ជាអគារប្រណិតគួរសម មានអាយុកាល តាំងពីសម័យអាណានិគម ដែលមានភាពគួរឱ្យកត់សម្គាល់ជាងអគារផ្សេងទៀត ដោយសារភាព សមសួនមិនស្រស់ឆើត ទោះបីជាហួសសម័យបន្តិចក៏ដោយ។

បន្ទាប់ពីទទួលទានអាហារថ្ងៃត្រង់រួចមក ពួកយើងម្នាក់ៗបានទៅកាន់បន្ទប់រៀងៗខ្លួន។ ដោយនឹក កូនស្រីទាំងពីរពេក ខ្ញុំក៏ដករូបថតពួកគេដែលទើបតែថតកាលពីពេលថ្មីៗនេះ ចេញពីកាបូបលុយ របស់ខ្ញុំ។ ពេលនោះ ខ្ញុំក៏ឮសំឡេងគោះទ្វាររបស់ខ្ញុំ។ គ្មានអ្វីត្រូវសង្ស័យនោះទេ គឺគ្មាននរណាក្រៅពី លោក អៀង សារី នោះឡើយ។ គាត់ចូលក្នុងបន្ទប់ខ្ញុំយ៉ាងប្រញាប់ប្រញាល់ ហើយទាញយករូប ថតពីក្នុងដៃខ្ញុំ រួចចេញទៅវិញយ៉ាងលឿនដូចពេលគាត់ចូលមកអ៊ីចឹងដែរ បន្ទាប់ពីបាននិយាយត្រឹម តែពាក្យថា៖ “អស់រយៈពេលដប់ឆ្នាំមកហើយដែលខ្ញុំមិនបានជួបកូនៗរបស់ខ្ញុំ!”។ សម្ដីនេះធ្វើឱ្យខ្ញុំ ត្រជាក់ខ្លួនស្រេប។ “ដប់ឆ្នាំ!”។ ខ្ញុំបែកពីកូនស្រីតែមួយថ្ងៃប៉ុណ្ណោះ ខ្ញុំនឹកពួកគេខ្លាំងណាស់រួចទៅ ហើយ។ ចុះបើបែកគ្នា “មួយឆ្នាំ” “ពីរឆ្នាំ” “ដប់ឆ្នាំ” តើវាទៅជាយ៉ាងណា? អូ! ព្រះជាម្ចាស់។ ខ្ញុំ សុខចិត្តមិនគិតដល់រឿងនេះវិញល្អជាង។

តាមពិត ខ្ញុំមិនបានចូលទៅតំបន់រំដោះភ្លាមៗនោះទេ។ លោក អៀង សារី បានទុកខ្ញុំជាមួយលោក ទន់ ជោតស៊ីរិន ឱ្យធ្វើការនៅស្ថានីយវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជាឈ្មោះ“សំឡេងរណសិរ្ស រួបរួមជាតិកម្ពុជា” ដែលដឹកនាំដោយភរិយារបស់គាត់ អ្នកស្រី អៀង សារី។ ខ្ញុំមិនអាចកំណត់ឱ្យ បានច្បាស់នូវកន្លែងដែលពួកយើងធ្វើការនោះទេ។ គឺនៅជាយក្រុងខាងលិចទីក្រុងហាណូយ ដោយ ជិះរថយន្ត១៥នាទីពីកណ្តាលរដ្ឋធានីវៀតណាម។ ពួកយើងមិនមានគ្នាច្រើនទេ គឺប្រហែលជា៣០ នាក់ ចែកចេញជាបីក្រុម៖ ក្រុមអ្នកចាស់ ដែលបានចាកចេញពីប្រទេសនៅឆ្នាំ១៩៥៤ ក្រោយពីការ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវស្តីពីឥណ្ឌូចិន ក្រុមបញ្ញវន្តដែលភាគច្រើនមកពី អឺរ៉ុប និងសហភាពសូវៀត ព្រមទាំងក្រុមកម្មាភិបាល និងសកម្មជនក្នុងប្រទេស ដែលជាក្រុម សិល្បៈរបស់វិទ្យុ “សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា”។

ពួកយើងធ្វើការនៅវិទ្យុនោះមុនបញ្ញវន្តល្បីៗមួយចំនួន ដូចជា លោក អ៊ិន សុភាព មកពីទីក្រុង ប៉ារីស លោក ឡុង ណូរិន មកពីទីក្រុងប្រាក និងលោក ហាក់ ស៊ាងឡាយនី មកពីទីក្រុងម៉ូស្គូ។ ក្នុងចំណោមអតីតអ្នកតស៊ូនៃទសវត្សរ៍ឆ្នាំ៤០ មានជាអាទិ៍ លោក សួ ផន ជាលេខាធិការផ្ទាល់

របស់លោក អៀង សារី និងលោក ជា សុទ្ធ ហៅ ចាន់ ជាអ្នកនិយាយវិទ្យុដ៏សំខាន់របស់ “សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា” ហើយក្រោយមកក្លាយជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ លោក គាត ឈន់ បានស្នាក់នៅជាមួយពួកយើងបានពីរបីខែ មុននឹងចូលទៅតំបន់រំដោះ។ ដូចគ្នាផងដែរចំពោះលោក ទីវ អុល ជាករីផ្លូវការនៃកម្ពុជាប្រជាធិបតេយ្យ។

ខ្ញុំជាអ្នកនិពន្ធដំណឹងអន្តរជាតិសម្រាប់វិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា។ ពេញមួយថ្ងៃ ពួកយើងមានការមមាញឹកគួរសមដែរ។ នៅពេលព្រឹក បន្ទាប់ពីភ្ញាក់ពីគេងនៅម៉ោង៥ (ដែលជាម៉ោងកំណត់) យើងធ្វើពលកម្មមួយម៉ោង។ ដោយសារខ្វះសម្ភារៈកសិកម្ម ពួកយើងម្នាក់ៗខ្នះខ្នែងប្រជែងគ្នាក្រោកឱ្យបានឆាប់ ដើម្បីទៅយកចបកាប់ និងចបជីកសម្រាប់ធ្វើការ។ ចំណែកខ្ញុំ ខ្ញុំមានជំនាញខាងស្រោចទឹកលាយជាមួយទឹកនោមនិងលាមកមនុស្ស និងសត្វ។ ខ្ញុំស្មានខុសថាសកម្មជនមកពីក្នុងប្រទេសមិនស្អប់ខ្ពើមការងារបែបនេះទេ។ ផ្ទុយទៅវិញ គឺពួកបញ្ញវន្តឯណោះទេដែលជាអ្នកស្នើសុំបំពេញភារកិច្ចគួរឱ្យខ្ពើមរអើមបំផុតនោះ។

គណៈប្រតិភូរបស់ FUNK និង GRUNK ដែលដឹកនាំដោយលោក ខៀវ សំផន និងលោក អៀង សារី ត្រូវបន្តទស្សនកិច្ចទៅកាន់តំបន់រំដោះនៃប្រទេសវៀតណាមខាងត្បូង និងឡាវ។ ខ្ញុំ និង ទន់ ជោតស៊ីរិន ត្រូវបានចាត់តាំងជាសមាជិកគណៈប្រតិភូ ដោយរួមទាំង សៀន អាន ផង ដែលកាលនោះជាឯកអគ្គរាជទូតនៃ GRUNK ប្រចាំនៅទីក្រុងហាណូយ។ ម្ចាស់ផ្ទះវៀតណាមបាននាំពួកយើងទៅកាន់ Khê Sanh ជាមូលដ្ឋានបន្ទាយទ័ពអាមេរិក ដែលត្រូវបានវាយយកដោយពួកវៀតកុងបន្ទាប់ពីចម្បាំងកាប់សម្លាប់គ្នាអស់រយៈពេលជាច្រើនខែរួចមក និងទៅខេត្ត Quang Tri ស្ថិតនៅជិតខ្សែស្របទី១៧។ ក្នុងចម្ងាយមួយគីឡូម៉ែត្រពីអាកាសយានដ្ឋានយោធានៃទីក្រុងនេះ ពួកយើងអាចមើលឃើញទង់ជាតិវៀតណាមខាងត្បូងបក់រវិចៗ។ បន្ទាប់មកទៀត ពួកយើងបានបន្តដំណើរទៅកាន់តំបន់រំដោះរបស់ប្រទេសឡាវ គឺខេត្ត Sam Neua និងខេត្ត Phong Saly។ តាមរយៈទស្សនកិច្ចរយៈពេលពីរថ្ងៃនេះ ខ្ញុំនៅចាំបានថា មិត្តឡាវបានឱ្យពួកយើងទទួលទានបាយដំណើបរហូត ហើយយើងត្រូវញ៉ាំឱ្យអស់សិន មុននឹងញ៉ាំម្ហូបផ្សេងទៀត។ ខ្ញុំក៏ចងចាំផងដែរថាជនជាតិឡាវ រួមទាំងថ្នាក់ដឹកនាំផងដែរ ចូលចិត្តរាំ ជាពិសេស បទរាំវង់។

បន្ទាប់ពីចាកចេញពីប្រទេសឡាវ គណៈប្រតិភូរបស់យើងបានត្រឡប់ទៅព្រំដែនវៀតណាមវិញ។ លោក ខៀវ សំផន និងលោក អៀង សារី ត្រូវត្រឡប់ទៅប្រទេសកម្ពុជាវិញ តាមផ្លូវលំហូជីមិញ ចំណែកខ្ញុំ ខ្ញុំនៅបន្តធ្វើការជាមួយអ្នកស្រី អៀង ធីរិទ្ធ នៅវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា នៅឯជាយក្រុងហាណូយ។

ដោយសារមិត្តរួមការងារមួយចំនួនបានចេញដំណើរទៅក្នុងប្រទេស ខ្ញុំទទួលភារកិច្ចថ្មីមួយទៀត គឺការបកប្រែសារក្នុងទម្រង់ជាកូដដែលផ្ញើតាមទូរពុម្ពពីតំបន់រំដោះ បន្ថែមពីលើការងាររបស់ខ្ញុំជាអ្នកទទួលខុសត្រូវសារប័ព្វអន្តរជាតិនៅវិទ្យុ "សំឡេងរណសិរ្សរួមរួមជាតិកម្ពុជា"។ នេះជាការងារគួរឱ្យធុញទ្រាន់ និងលំបាក ដែលតម្រូវឱ្យយើងអត់ដេកពេញមួយយប់ជាញឹកញាប់។ រឿងតែមួយគត់ដែលធ្វើឱ្យមានការធូរស្រាលនោះគឺថា អ៊ុន សុភាព ហៅមិត្តមី ដែលធ្វើការជាមួយខ្ញុំ មិនសូវភ្លេចឆុងកាហ្វេមួយពែងធំដ៏ឆ្ងាញ់ ធ្វើឱ្យយើងនឹកឃើញមួយភ្លែតៗនូវពេលវេលាដ៏ល្អកន្លងទៅនៅទីក្រុងប៉ារីស។

ដោយសារខ្ញុំធ្វើជាអ្នកឆ្លើយឆ្លងព័ត៌មានឱ្យទីភ្នាក់ងារព័ត៌មានខ្មែរ(A.K.I) ប្រចាំនៅទីក្រុងប៉េកាំង ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៤ ភារកិច្ចថ្មីរបស់ខ្ញុំគឺនឹងត្រូវធ្វើជាប្រធានទីភ្នាក់ងារប្រចាំនៅទីក្រុងហាណូយ។ ប៉ុន្តែមិនដឹងដោយសារមូលហេតុអ្វីនោះទេ រឿងបែបនេះមិនបានកើតឡើងឡើយ។ ដូច្នេះខ្ញុំត្រូវបន្តនៅស្ថានីយវិទ្យុសំឡេងរណសិរ្សរួមរួមជាតិកម្ពុជាតទៅទៀត ជាមួយអ្នកស្រី អៀង ធីរិទ្ធ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៥ ទើបខ្ញុំចូលទៅតំបន់រំដោះ។

## ២- <u>ការវិលត្រឡប់ទៅកាន់ប្រទេសវិញ តាមផ្លូវលំហូជីមិញ</u>

ការធ្វើដំណើរតាមផ្លូវលំហូជីមិញគឺជាការដកពិសោធដ៏ពិតប្រាកដមួយសម្រាប់ខ្ញុំ។ ប៉ុន្តែខ្ញុំត្រូវប្រឈមមុខតែនឹងឧបសគ្គធម្មជាតិប៉ុណ្ណោះ ដោយសារអាមេរិកឈប់ទម្លាក់គ្រាប់បែក បន្ទាប់ពីមានកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៧៣។ ក្នុងដំណើរនេះ ខ្ញុំនៅចងចាំបានពីទិដ្ឋភាពដ៏សោកសៅនៃក្រុងវីញ ដែលត្រូវបានបំផ្លាញទាំងស្រុង អាកាសយានដ្ឋានយុទ្ធសាស្ត្រខេត្តដាណាងដ៏ស្ងាត់ជ្រងំ និងក្រុង Pleiku ដែលនៅទីនោះជនភៀសខ្លួនមកពីតំបន់ជិតខាងនៅលាយឡំគ្នាជាមួយនឹងប្រជាជនមូលដ្ឋាន យ៉ាងច្រើនចម្លែក។

## VI- នៅលើទឹកដីកំណើតសាជាថ្មី

### ១- ការមកដល់ខេត្តរតនគិរីលើកដំបូង

នៅពេលពួកយើងឈានជើងជាន់ដីខេត្តរតនគិរីភ្លាម ខ្ញុំប្រញាប់ច្បាមក្ដាប់ក្នុងដៃនូវដីកំណើតដែលខ្ញុំបានឃ្លាតឆ្ងាយអស់រយៈពេលជិតកន្លះទសវត្សរ៍មកហើយ។ ក្នុងក្រសែភ្នែករបស់ពួកយើង ខេត្តរតនគិរីតំណាងឱ្យទឹកដីកំណើតនៃបដិវត្តន៍ ជាកន្លែងដែលមេដឹកនាំរបស់ពួកយើងជ្រកពួន និងចាប់ផ្ដើមការងារបណ្ដុះបណ្ដាលសកម្មជនស្នូលដើម្បីតស៊ូនាពេលខាងមុខ។ ពេលនោះ ខ្ញុំរំភើបយ៉ាងខ្លាំង។ ដូច្នេះ ក្ដីស្រមៃរបស់ខ្ញុំតាំងពីយូរណាស់មកហើយក៏បានក្លាយជាការពិត។

ក្នុងនាមជាប្រធានក្រុមធ្វើដំណើរ ខ្ញុំបានចងអង្រឹងនឹងដើមឈើឱ្យសមាជិកក្រុមសម្រាកពេលយប់។ នៅពេលដែលអង្រឹងរបស់អ្នកផ្សេងជាប់បានល្អ អង្រឹងរបស់ខ្ញុំដាច់ខ្សែ នៅពេលខ្ញុំដាក់ខ្លួនដេកភ្លាម។ សំណាងដែរ ខ្ញុំចងអង្រឹងផុតពីដីតែបន្តិចប៉ុណ្ណោះ ធ្វើឱ្យខ្ញុំមានរបួសដាច់រលាត់បន្តិចបន្តួចប៉ុណ្ណោះ។ ពួកយើងបានទៅដល់ក្រុងស្ទឹងត្រែងយ៉ាងលំបាក។ ផ្លូវលេខ១៩ ដែលសំបូរទៅដោយគ្រលុក ធ្វើឱ្យពួកយើងលំបាកក្នុងការធ្វើដំណើរយ៉ាងខ្លាំង។ វត្តមាននៃគ្រាប់បែកមិនទាន់ផ្ទុះមួយគ្រាប់នៅគែមផ្លូវរឹតតែធ្វើឱ្យការធ្វើដំណើររបស់ខ្ញុំមានការលំបាកឡើង។

នៅមុនសង្គ្រាម ខ្ញុំមិនធ្លាប់ស្គាល់ក្រុងស្ទឹងត្រែងទេ ទោះបីជាខ្ញុំជាអ្នកខេត្តក្រចេះជាប់នោះក៏ដោយ។ ចាប់ពីអតីតទីរួមខេត្ត មិនមាននៅសល់អ្វីជាដុំកំភួននោះទេ ក្រៅតែពីអគារបាក់បែក ដែលដុះរុំព័ទ្ធទៅដោយរុក្ខជាតិ។

### ២- អ្នកស្នាក់នៅមន្ទីរ ប-២០

ក្នុងខែកុម្ភៈនេះ កំពស់ទឹកទន្លេមេគង្គនៅទាបបំផុត ការធ្វើដំណើរតាមផ្លូវទឹកឡើងទៅស្រុកសំបូរមានគ្រោះថ្នាក់យ៉ាងខ្លាំង ដោយសារមានទឹកហូរខ្លាំងជាច្រើនកន្លែង។ ពួកយើងជិះកាណូតម៉ាស៊ីនពីរ។ កាណូតរបស់ខ្ញុំត្រូវខ្យល់ព្យុះបោកបក់នៅម្តុំថ្មក្រែ ខាងលើក្រចេះបន្តិច ហើយរិះតែនឹងក្រឡាប់។ មេក្រុមការពារ ជាកម្មាភិបាលជនជាតិឡាវ ដែលមិនសូវមានទម្លាប់នឹងការធ្វើដំណើរតាមទន្លេ មានការភ័យខ្លាច ហើយបានបញ្ជាឱ្យអ្នកបើកកាណូតទៅតាមបណ្ដោយច្រាំង ដែលតាមពិត ត្រូវបើកកាត់ទទឹងតែម្តង ដោយត្រូវដំឡើងម៉ូទ័រឱ្យខ្លាំង។

អ្វីដែលខ្ញុំសោកស្ដាយបំផុតនោះ គឺមិនអាចឈប់នៅមុខស្រុកកំណើតរបស់ខ្ញុំ នៅភូមិជ្រោយអំពិល ឃុំចំបក់ ស្រុកព្រែកប្រសប់ ខេត្តក្រចេះ ដែលខ្ញុំបានចាកចេញនៅមុនពេលបោះឆ្នោតជាទូទៅឆ្នាំ ១៩៥៥ បន្តិច ដើម្បីគេចពីការចាប់ខ្លួនដោយថាហេតុ ដោយសារតែទស្សនៈនយោបាយរបស់ខ្ញុំ។

នៅខណៈដែលកាណូតមួយទៀតទៅដល់មុខភូមិរបស់ខ្ញុំ នៅប្រហែលម៉ោងប្រាំល្ងាច កាណូតរបស់ខ្ញុំទៅដល់នៅពេលយប់ងងឹត។ ដូច្នេះ ខ្ញុំមិនអាចមើលស្គាល់ផ្ទះគ្រួសាររបស់ខ្ញុំ និងភ្នំសុព័រកាឡី ដែលលយចូលខ្សែទឹកទន្លេមេគង្គនោះទេ។

ពួកយើងបានមកដល់ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជាគោលដៅធ្វើដំណើរចុងក្រោយរបស់ពួកយើង ដោយសុវត្ថិភាព ទោះបីជាពួកយើងត្រូវដេកនៅលើកាណូតក៏ដោយ។ ស្អែកព្រឹក ពួកយើងជិះរថយន្តកាំម៉ុងទៅមន្ទីរ ប-២០។ ប-២០គឺជាមន្ទីរកសាងពួកបញ្ញវន្តមកពីបរទេស ស្ថិតនៅប្រមាណដប់គីឡូម៉ែត្រ ពីស្រុកស្ទឹងត្រង់។ នៅម្ដុំៗនោះ មានមន្ទីរកសាងបែបនេះជាច្រើន។ មន្ទីរ ប-២០ ត្រូវបានគេស្គាល់ និងមានមនុស្សចេញចូលច្រើនជាងគេ។ នៅទីនោះ ការងារជាចម្បងរបស់ពួកយើង គឺកាស់ដើមចេក ហើយដឹកយកទៅកន្លែងមួយទៀតឱ្យក្រុមមួយទៀតដាំ បន្ទាប់ពីជីករណ្ដៅធំៗ។ ការងារនេះមិនសូវជានឿយហត់ពេកទេ ហើយថែមទាំងមានសេរីភាពគួរសមទៀតផង ពីព្រោះមិនមានការឃ្លាំមើលទេ។ ក្នុងពេលមួយថ្ងៃ ខ្ញុំមិនដែលកាស់បានលើសពី ២០ ដើមនោះទេ។

ថ្ងៃអាទិត្យ ពួកយើងផ្លាស់ប្ដូរសកម្មភាព។ ពេលព្រឹក គឺមានការប្រជុំប្រចាំសប្ដាហ៍។ ការប្រជុំនេះមិនលើសពីមួយម៉ោងនោះទេ ព្រោះគេនិយាយផ្ដោតជាសំខាន់តែទៅលើសកម្មភាពបង្កបង្កើនផល។ មន្ទីរ ប-២០ហាក់ដូចជាមិនមានមុខងារនយោបាយនោះទេ គឺវាជាមជ្ឈមណ្ឌលសំចត និងសង្កេតមុននឹងអ្នករស់នៅទីនោះត្រូវបានចាត់តាំងឱ្យទទួលភារកិច្ចសមស្របណាមួយ។

មន្ទីរ ប-២០ សំបូរទៅដោយរុក្ខជាតិហូបផ្លែគ្រប់ប្រភេទ។ ក្រៅពីចេក គេឃើញមានស្វាយ ម្នាស់ មង្ឃុត គូលែន ល្ហុង និងធូរេន។ យើងអាចញ៉ាំផ្លែឈើទាំងនេះបានដោយសេរី។

### ៣- ជាមួយ គាត ឈន់ នៅក្រសួងការបរទេស (ប-១)

គឺនៅមន្ទីរ ប-២០ ដែលពួកយើងដឹងអំពីការរំដោះទីក្រុងភ្នំពេញ។ ក្មេងស្រីម្នាក់ ជាអ្នកទទួលបន្ទុកខាងទូរពុម្ព ទើបតែបកស្រាយពាក្យដូចតទៅនេះ៖ “ព្រឹកនេះ ប្រមាណជាម៉ោង៩ និង៣០នាទី ទីបំផុត កងទ័ពរបស់យើងបានរំដោះទីក្រុងភ្ន...”។ នាងមិនបានរង់ចាំទទួលសាររហូតដល់ចប់នោះទេ ក៏បានរត់ចេញពីកន្លែងស្នាក់នៅរបស់នាង ដើម្បីយកដំណឹងមកប្រាប់ពួកយើង។ ពេលនោះ ពួកយើងមានការសប្បាយចិត្តយ៉ាងខ្លាំង [...]

[...] ឆ្នាំ១៩៧៥ គេបានភ្នាល់ជាមួយ ប៉ុល ពត៖ “ខ្ញុំទាយថារបបរបស់លោកមិនអាចរស់រានមានជីវិតលើសពីបីឆ្នាំនោះទេ!”។ គួរតែនិយាយជាពាក្យសម្រាលថា ប៉ុល ពត មិនសូវទទួលយកពាក្យបណ្ដាសានេះទេ។ ដោយយល់ឃើញថាខ្លួនទទួលរងនូវការគំរាមកំហែង លោក ហ៊ូ យន់ បានគិតទុកជាមុននូវការធ្វើអត្តឃាតរួចទៅហើយ។ អង្គរក្សរបស់លោកបានស្នើជាច្រើនដងឱ្យលោករត់គេចខ្លួនទៅទិសបស្ចិម។ ប៉ុន្តែ គាត់បដិសេធ ពីព្រោះគាត់ទទូចថា ទោះជាស្លាប់ ឬរស់ក៏ដោយ ក៏គាត់ត្រូវតែនៅជិតប្រជាជនរបស់គាត់ ដើម្បីរួមសុខរួមទុក្ខជាមួយពួកគេ។ នៅពេលប្រធានសន្តិសុខនៃគណៈមជ្ឈិមបក្សមកប្រកាសថា ប៉ុល ពត មានបំណងចង់ជួបលោក លោក ហ៊ូ យន់ បានដកកាំភ្លើងបម្រុងបាញ់ក្បាលខ្លួនឯង ព្រោះលោកដឹងថាថ្ងៃអវសានរបស់លោកមកដល់ហើយ។ ប៉ុន្តែដោយយល់ច្រឡំចំពោះកាយវិការរបស់លោក អ្នកយាមស្មានថាលោកចង់សម្លាប់គាត់។ អ្នកយាមបានដកកាំភ្លើងបាញ់សម្លាប់លោកភ្លាមមួយរំពេចទៅ។ បញ្ញវន្តដ៏ឆ្នើម និងសុចរិតបំផុតមួយរូបនៃប្រទេសកម្ពុជា បានបាត់បង់ជីវិត តាមរបៀបនេះ ។

យើងបានទៅដល់ទីក្រុងភ្នំពេញ ប្រហែលជាម៉ោង១២ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥។ ថ្ងៃនោះមានតម្លៃចំពោះខ្ញុំណាស់ ពីព្រោះជាថ្ងៃខួបកំណើតរបស់ភរិយាខ្ញុំ ឡូរ៉ង់ ហើយវាក៏ជាថ្ងៃដែលខ្ញុំបានចាកចេញពីទីក្រុងប៉េកាំងទៅកាន់តំបន់រំដោះកម្ពុជាផងដែរ។

នៅតាមតិរវិថី មុខព្រះបរមរាជវាំង ពួកយើងត្រូវបានទទួលយ៉ាងកក់ក្ដៅដោយលោក សេង ស៊ូហុង ជាក្មួយរបស់ ប៉ុល ពត និងជាអគ្គលេខាធិការក្រសួងការបរទេស ត្រូវជាជំនួយការផ្ទាល់ការរបស់លោក អៀង សារី។ ខ្ញុំកោតសរសើរមិនឈប់ចំពោះយុវជនមួយរូបនេះ ដែលមានរូបសម្បត្តិស្រស់ស្អាត រួសរាយរាក់ទាក់ និងទឹកមុខរីករាយ។ ក្នុងអំឡុងរយៈពេលប៉ុន្មានឆ្នាំនៃរបបប៉ុលពតដ៏គួរឱ្យភ័យខ្លាច យុវជននេះតំណាងឱ្យផ្នែកស្លូតនៃបដិវត្តន៍ គេតែងតែមានឥរិយាបទត្រឹមត្រូវជានិច្ចជា

មួយបញ្ញវន្តដូចជាពួកយើង ចេះយោគយល់ យល់ដឹងអំពីបំណងប្រាថ្នារបស់ពួកយើង និងមានសណ្ដានចិត្តល្អ។

នៅពេលលោក អ៊ុន សុភាព ទៅធ្វើការនៅក្រសួងព័ត៌មាន ខ្ញុំនៅជាមួយលោក គាត ឈន់ និង លោក កែវ បូរី (វិស្វករមកពីទីក្រុងម៉ូស្គូ) ដើម្បីរៀបចំក្រសួងឡើងវិញ។ ពួកយើងស្នាក់នៅក្នុង “ផ្ទះពណ៌ផ្កាឈូក” ជិតព្រះបរមរាជវាំង អស់រយៈពេលពេញមួយខែមិថុនា ឆ្នាំ១៩៧៥។ នេះគឺជាភូមិគ្រឹះដ៏ស្រស់ស្អាត ជាកម្មសិទ្ធិរបស់ព្រះអង្គម្ចាស់ក្សត្រីពៅ ជាមហេសីមួយអង្គរបស់សម្ដេចនរោត្តម សីហនុ។ ក្នុងរបបសាធារណរដ្ឋខ្មែរ ភូមិគ្រឹះនេះត្រូវបានប្រើជាការិយាល័យរបស់អនុព័ន្ធយោធានៃព្រះរាជាណាចក្រថៃ។ ពួកយើងទាំងបីនាក់ ខ្ញុំ គាត ឈន់ និងបូរី គឺជាស្នូលនៃអ្វីដែលក្រោយមក ក្លាយជាក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ។ លោក អៀង សារី ដែលជាចៅហ្វាយនាយរបស់ពួកយើង បានមកសួរសុខទុក្ខពួកយើងម្ដងម្កាល។ នៅដើមខែកញ្ញា លោក អៀង សារី បានប្រាប់ខ្ញុំ និងលោក គាត ឈន់ ថាពួកយើងត្រូវចូលរួមជាគណៈប្រតិភូកម្ពុជា នៅសន្និសីទថ្នាក់ក្រសួងនៃប្រទេសមិនចូលបក្សសម្ព័ន្ធ ដែលនឹងប្រព្រឹត្តទៅក្នុងអំឡុងខែកញ្ញានេះ នៅទីក្រុងលីម៉ា (ប្រទេសប៉េរូ)។

ឥស្សរជនល្បីៗមួយចំនួន ដូចជា លោក តូច ភឿន រដ្ឋមន្ត្រីក្រសួងសាធារណការ លោក ឈូក ម៉ឹងម៉ៅ និង លោក ភន់ ផេង ជាមេដឹកនាំចលនាជាតិនិយមទីក្រុង ក៏បានមកសួរសុខទុក្ខពួកយើង នៅផ្ទះពណ៌ផ្កាឈូកផងដែរ។ គឺនៅផ្ទះនេះ ហើយដែលខ្ញុំបានដឹងពីជោគវាសនារបស់លោក ខៀវ កុមារ ជាបញ្ញវន្តចម្រើននិយមដ៏ល្បី និងពីមរណភាពរបស់មិត្តខ្ញុំម្នាក់ឈ្មោះ ផាន់តារា ដោយសាររោគហឺត។ នៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គាត់មានតែខោខ្លី និងអាវមួយចង្កេះប៉ុណ្ណោះ ដោយគាត់ជឿថាគាត់នឹងត្រឡប់មកវិញ ក្នុងរយៈពេលពីរ ឬបីថ្ងៃក្រោយ។

ម្យ៉ាងវិញទៀត ខ្ញុំត្រូវគូសបញ្ជាក់ថា អ្នកស្គាល់ទីមួយដែលបានជួបនៅទីក្រុងភ្នំពេញ នៅពេលខ្ញុំចុះពីកាណូតនៅស្រុកស្ទឹងត្រង់ គឺគ្មាននរណាក្រៅពី ម៉ុល ភូរិ មិត្តរបស់ខ្ញុំនៃក្រុម ម៉ាក្សលេនីននិយមនៅក្រុងប៉ារីសនោះទេ។ នៅចំពោះមុខការភ្ញាក់ផ្អើលរបស់ខ្ញុំដែលបានជួបគាត់នៅទីក្រុងភ្នំពេញ ខណៈដែលអ្នកភាគច្រើនមកពីទីក្រុងប៉ារីសទទួលរងនូវជោគវាសនាដូចគ្នានឹងប្រជាជនដទៃទៀតដែរ និងដោយដឹងមុនពីសំណួរដែលខ្ញុំត្រូវសួរ ភូរិ បានប្រាប់ខ្ញុំថាអង្គការទុកគាត់សម្រាប់ជួយរៀបចំទីក្រុងភ្នំពេញឡើងវិញ។ តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ទេ។

អារម្មណ៍ដំបូងដែលខ្ញុំទទួលដឹង នៅពេលទៅដល់ទីក្រុងភ្នំពេញវិញ បន្ទាប់ពីបានចាកចេញអស់រយៈពេល១៨ឆ្នាំ គឺភាពព្រងើយកន្តើយយ៉ាងចម្លែក។ ប៉ុន្តែ ខ្ញុំយល់ឃើញថាវាធំទូលាយបន្តិច បើប្រៀបជាមួយទីក្រុងដែលខ្ញុំធ្លាប់រស់នៅ ដូចជាម៉ូស្គូ ឬប៉េកាំង។ ភ្នំពេញ ដែលកាលពីមុនត្រូវបានប្រសិទ្ធនាមថាជាគ្រាប់គុជអាស៊ីអាគ្នេយ៍ ឥឡូវនេះ ហាក់ដូចជាគ្មានមន្តស្នេហ៍ និងភាពទាក់ចិត្តពិសេសអ្វីសោះចំពោះខ្ញុំ។ ខ្ញុំលែងឃើញទីក្រុងដែលបានធ្វើឱ្យខ្ញុំចាប់ចិត្តប្រតិព័ទ្ធទៀតហើយ។

## VII- ការឆ្លងកាត់វាលរហោស្ថាន ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

### ១- អ្នកស្នាក់នៅមន្ទីរ ប-១

បន្ទាប់ពីបានស្នាក់នៅពេញមួយខែមិថុនា នៅផ្ទះពណ៌ផ្កាឈូក ខ្ញុំ និងលោក គាត ឈន់ បានទទួលបញ្ជាឱ្យរើមកនៅ “ផ្ទះកោងកញ្ចក់” ជាអគារអតីតទីស្តីការគណៈរដ្ឋមន្ត្រី ហើយក្លាយជាមន្ទីរ ប-១ ដ៏ល្បីល្បាញនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណែកឯ បូរី គាត់ចូលទៅធ្វើការនៅក្រសួងរ៉ែ ដែល បន្តិចក្រោយមក គាត់ក៏បាត់ខ្លួន។

នៅមន្ទីរ ប-១ ពួកយើងត្រូវធ្វើការបោសសម្អាតទីតាំង ដើម្បីយកធ្វើជាការិយាល័យ។ ការិយាល័យរបស់ខ្ញុំត្រូវបានរៀបចំនៅជាប់ក្រោយទ្វារចូលអគារ។ រៀងរាល់ព្រឹក មុននឹងទៅកាន់ការិយាល័យរៀង១ខ្លួន កម្មាភិបាលក្រសួងទាំងអស់មានទម្លាប់ជួបប្រជុំគ្នា នៅក្នុងការិយាល័យរបស់ខ្ញុំ ដែលនៅទីនោះ ការពិភាក្សាគ្រប់ប្រភេទទាំងអស់ត្រូវធ្វើឡើងយ៉ាងឆាប់រហ័ស ហើយជួនកាល ត្រូវបានកាត់ផ្តាច់ដោយការមកដល់របស់អ្នកស្រី សូ សែ ជាលេខាធិការសាខាបក្សនៅក្រសួង។

លោក ទន់ ជោតស៊ីរិន បានមកចូលរួមជាមួយពួកយើងពីរបីថ្ងៃ មុននឹងចេញទៅទទួលខុសត្រូវលើជនរួមជាតិមកពីទីក្រុងប៉េកាំង ដែលស្នាក់នៅក្នុងអគារនៃអតីតក្រសួងការពារជាតិ ជិតមន្ទីរ ប-១។ ក្រោយមកលោក ស៊ីរិន ភរិយាឈ្មោះវីផា និងម្តាយក្មេក ត្រូវបានបោសសម្អាត ដោយខ្ញុំមិនដឹងពីមូលហេតុនោះទេរហូតមកដល់ថ្ងៃនេះ។

### ២- ការមកដល់ទីក្រុងភ្នំពេញរបស់ ឡូរ៉ង់ ពិច ណារ៉ែន និងសុខា

គឺស៊ីរិន ជាអ្នកប្រាប់ខ្ញុំពីកាលបរិច្ឆេទមកដល់ទីក្រុងភ្នំពេញរបស់ ឡូរ៉ង់ ណារ៉ែន និងសុខា ដែលបានគ្រោងនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៥។ ខ្ញុំរង់ចាំថ្ងៃនោះយ៉ាងអន្ទះសា និងដោយព្រួយបារម្ភ។ តើឡូរ៉ង់ចេះសម្របខ្លួនទៅនឹងល័ក្ខខ័ណ្ឌជីវិតថ្មី នៅក្នុងប្រទេសមួយដែលនាងស្គាល់តែតាមរយៈការអានដែរឬទេ? ការស្នាក់នៅរយៈពេលប្រាំឆ្នាំនៅទីក្រុងប៉េកាំង គឺជាការលំបាកវេទនាណាស់ទៅហើយសម្រាប់នាង។ ប៉ុន្តែនៅទីនោះ មិនមានអ្វីខ្វះខាតនោះទេ។

ការសម្របខ្លួនផ្នែកសម្ភារៈគឺជាការលំបាកមួយដ៏ធ្ងន់សម្រាប់ឡូរ៉ង់រួចទៅហើយ ពីព្រោះនាងធ្លាប់តែរស់នៅក្នុងជីវភាពមួយផ្សេង។ ប៉ុន្តែការសម្របខ្លួនផ្នែកស្មារតី និងផ្លូវចិត្ត ជាបញ្ហាប្រឈមពិតប្រាកដសម្រាប់នាង។ តើនាងអាចនឹងមានជោគជ័យឬទេ នៅកន្លែងដែលមនុស្សជាច្រើននៅក្នុងល័ក្ខខ័ណ្ឌស្រដៀងគ្នានេះ បានបរាជ័យរួចទៅហើយនោះ? ហើយចុះកូនស្រីទាំងពីរដែលនៅទន់ខ្សោយ និងមិនមានការគាំពារ តើពួកនាងចេះរស់នៅក្នុងបរិយាកាសថ្មីស្រឡាង និងមិនទៀងទាត់ដែរឬទេ?

ខ្ញុំបានចាកចេញពីប្រពន្ធនិងកូនស្រីរបស់ខ្ញុំរយៈពេលតែមួយឆ្នាំបួនខែនិងដប់ប្រាំថ្ងៃប៉ុណ្ណោះ ក៏ប៉ុន្តែវាប្រៀបបានដូចជារយៈពេលមួយដ៏យូរអង្វែងសម្រាប់ខ្ញុំអញ្ចឹង។ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានការពិបាកយ៉ាងខ្លាំងក្នុងការសម្របខ្លួនទៅនឹងជីវិតថ្មីរបស់ខ្ញុំនៅប្រទេសកម្ពុជា ជាពិសេសទៅនឹងចលនាដែលចេះតែឈានទៅមុខ ហើយដែលបានគ្លចយកជីវិតជនស្លូតត្រង់អស់ជាច្រើនទៅជាមួយទៀតផង។

ទាល់តែប្រាំថ្ងៃក្រោយពេលមកដល់របស់ប្រពន្ធនិងកូនស្រីខ្ញុំ ទើបគេអនុញ្ញាតិឱ្យខ្ញុំទៅជួបពួកគេដែលបានមកជួបជុំជាមួយបងប្អូនជនរួមជាតិរបស់យើងដែលមកពីទីក្រុងប៉េកាំង។ ពួកគេបានមកនៅជុំគ្នាជាមួយខ្ញុំនៅមន្ទីរ ប-១ នៅបីថ្ងៃក្រោយពេលដែលខ្ញុំបានទៅជួបពួកគេនោះ។

ឡូរ៉ង់សង្ឃឹមថាអាចបន្តការងាររបស់គាត់ជាអ្នកបកប្រែនិងជាលេខាវាយអង្គុលីលេខ ដូចកាលនៅទីក្រុងប៉េកាំងដែរ។ ប៉ុន្តែគាត់មានការខកចិត្តជាខ្លាំង នៅពេលដែលគេមិនបានប្រគល់ការងារនេះឱ្យគាត់ភ្លាមៗនោះ។ គេបានដាក់គាត់ឱ្យស្ថិតនៅក្នុងស្ថានភាពសង្កេតការណ៍និងរង់ចាំទៅវិញ។

ដើម្បីរកអ្វីមួយធ្វើ និងដោយគំនិតផ្តួចផ្តើមរបស់គាត់ ឡូរ៉ង់ក៏បានចាប់បកប្រែជាភាសាបារាំងនូវរាល់វិចារណកថា និងអត្ថបទសំខាន់ៗបំផុតនៃ "សំឡេងកម្ពុជាប្រជាធិបតេយ្យ"។ ជារៀងរាល់

ល្ងាច គាត់តែងតែយកអត្ថបទដែលគាត់ទើបតែបកប្រែហើយនៅពេលថ្ងៃមកឱ្យខ្ញុំកែ និងដើម្បីឱ្យខ្ញុំប្រើប្រាស់វាឱ្យមានប្រយោជន៍នៅពេលក្រោយ។ ក្រោយមក ខ្ញុំក៏អាចធ្វើឱ្យគេចេញផ្សាយអត្ថបទបកប្រែទាំងនេះ នៅក្នុងព្រឹត្តិបត្រទីភ្នាក់ងារព័ត៌មានកម្ពុជា ដោយនៅពេលនោះ ខ្ញុំគឺជាអគ្គនាយកទីភ្នាក់ងារនេះ ហើយក៏ជាអគ្គនាយកនៃនាយកដ្ឋានសារព័ត៌មាននិងព័ត៌មានរបស់ក្រសួងផងដែរ។

ទោះបីជាឡូរ៉ង់មានបំណងល្អ និងមានចំណេះដឹងគួរឱ្យកោតសរសើរដែលអាចនាំមកនូវប្រយោជន៍ក៏ដោយ ក៏គាត់នៅតែត្រូវគេទុកឱ្យនៅក្រៅសហគមន៍ន៍ដដែល។ ដើម្បីបំភ្លេចចោលនូវអារម្មណ៍ដែល ត្រូវគេបោះបង់ចោល គាត់ក៏បានចាប់ធ្វើការងារដាំដំណាំយ៉ាងមោះមុត ជាពិសេសគឺការដាំដើមផ្កាខាត់ណា។ នៅក្នុងការងារដាំដំណាំនេះ គាត់បានទទួលជោគជ័យទាល់តែមែនទែនរហូតដល់អ្នកនៅ មន្ទីរ ប-១ ទាំងអស់មានការកោតសរសើរពីស្នាដៃនិងការស្ងិតស្ងាញរបស់គាត់។

ភាពជោគជ័យដ៏វិសេសវិសាលរបស់គាត់នេះ មិនអាចផ្សះភ្ជិតមុខរបួសរបស់គាត់ដែលបានបើករួចហើយនោះទេ ហើយមុខរបួសនេះក៏នឹងមិនបិទមកវិញជារៀងរហូត។ នៅពេលដែលខ្ញុំបានដឹងពីជម្រៅនិងភាពដែលមិនអាចព្យាបាលបាននៃមុខរបួសនេះ គឺវាហួសពេលបាត់ទៅហើយ។

ឡូរ៉ង់បានធ្វើអ្វីៗយ៉ាងអស់ពីសមត្ថភាពដើម្បីបុព្វហេតុបដិវត្តន៍នៃប្រជាជនកម្ពុជា ដោយគាត់ជឿថាជាបុព្វហេតុត្រឹមត្រូវ និងថ្លៃថ្នូរ។ ប៉ុន្តែ ការពិតវាមិនមែនដូច្នោះនោះទេ។ ការខកចិត្តរបស់គាត់មានទំហំធំស្មើនឹងការលះបង់ដែលគាត់បានមានមុននឹងមកប្រទេសកម្ពុជាដែរ។

ទោះបីជាបានទទួលនូវការបណ្តុះបណ្តាលនិងការអប់រំនៅប្រទេសលោកខាងលិចក៏ដោយ ក៏ឥទ្ធិពលនៃបុរេវិនិច្ឆ័យជាតិនិយមដែលមានមកលើខ្ញុំ មិនអាចឱ្យខ្ញុំយល់បាននូវការផ្លាស់ប្តូរផ្លូវចិត្តយ៉ាងយឺតៗ និងមិនអាចចៀសបានរបស់ឡូរ៉ង់ដែរ។ ខ្ញុំត្រូវបង់ការខូចខាតវិញយ៉ាងច្រើនសម្រាប់ការដែលមិនយល់និងមិនស្គាល់ច្បាស់នេះ។ សូម្បីតែរហូតមកដល់សព្វថ្ងៃនេះក៏ដោយ ក៏ការឈឺចាប់ពើតផ្សានៅតែរួមរឹតខ្លួនខ្ញុំ រាល់ពេលដែលខ្ញុំនឹកគិតទៅដល់ការឈឺចុកចាប់ផ្លូវចិត្តដែលឡូរ៉ង់បានទទួលរង ដែលជាផលវិបាកនៃការរៀបអាពាហ៍ពិពាហ៍របស់យើង និងជាពិសេសជាផលវិបាកនៃការមិនយល់របស់ខ្ញុំ។

ជីវិតនិងការងាររបស់ខ្ញុំនៅក្រសួងការបរទេស នាទីក្រុងភ្នំពេញ បានដំណើរការទៅក្នុងសង្វាក់មួយ ដែលពិបាកនឹងទ្រាំទ្របាន។

មន្ទីរ ប-១ គឺជាបណ្តុំនៃអគារដែលមានលក្ខណៈខុសៗគ្នា។ វាមានអគារមេដែលគេហៅជាទូទៅថា ជា"ផ្ទះកោងកញ្ចក់" ដែលជាអតីតអគារនៃទីស្តីការគណៈរដ្ឋមន្ត្រី នៅលើផ្លូវទៅពោធិចិនតុង។ ប៉ុន្មានថ្ងៃក្រោយពីការរំដោះ គាត ឈន់ បុរី និងខ្ញុំត្រូវបានគេចាត់តាំងឱ្យរៀបចំក្រសួងការបរទេស ដែលរួមមានប្រាំនាយកដ្ឋាន ដូចជានាយកដ្ឋាននយោបាយទូទៅ លេខាធិការដ្ឋាន នាយកដ្ឋានពិធីការ នាយកដ្ឋានអាស៊ី និងនាយកដ្ឋានអឺរ៉ុប។ ខ្ញុំត្រូវបានគេតែងតាំងជាអគ្គនាយកនៃនាយកដ្ឋានអឺរ៉ុប។ ដោយសារឋានៈនេះ គេចាត់តាំងឱ្យខ្ញុំទៅទទួលអ្នកការទូតយូហ្គោស្លាវី រូម៉ានី ស្វីស ស៊ុយអែត និងអាល់បានី។ ក្នុងចំណោមអ្នកដែលមកដល់មុនគេ ក៏មានឯកអគ្គរដ្ឋទូតស្វីសដែលត្រូវបានតែងតាំងនៅទីក្រុងប៉េកាំងផងដែរ។ គាត់ចូលចិត្តពិភាក្សាជាមួយខ្ញុំ ជាពិសេសអំពីការប្រកាសខ្លះៗនៃ "សំឡេងកម្ពុជាប្រជាធិបតេយ្យ" ដែលបានផ្សាយថាអ្នកក្រីក្រនៅទ្វីបអឺរ៉ុបនិងនៅសហរដ្ឋអាមេរិក នៅតែបន្តស្លាប់ដោយសារការស្រេកឃ្លាន។ គាត់រិះគន់ជាពិសេសនូវការចេញផ្សាយរបស់"សំឡេងកម្ពុជាប្រជាធិបតេយ្យ" ដែលបានរិះគន់យ៉ាងខ្លាំងក្លាពីវណ្ណៈគហបតីថាជាវណ្ណៈអាប់ឱន។

មានរឿងមួយទៀតដែលគួរឱ្យកត់ត្រាទុកដែរនោះ គឺថាមានព្រឹកមួយ នៅខែតុលា ឆ្នាំ១៩៧៦ ខ្ញុំត្រូវធ្វើជាអ្នកបកប្រែឱ្យ លោក ខៀវ សំផន ដែលទទួលសារតាំងពីឯកអគ្គរដ្ឋទូតអាល់បានីទីមួយ ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ តាមពិត ឯកអគ្គរដ្ឋទូតអាល់បានីរូបនេះ គឺជាមិត្តភក្តិខ្ញុំម្នាក់ដែរ។ ខ្ញុំបានស្គាល់គាត់នៅទីក្រុងប៊ុយដាប៉ែស (ប្រទេសហុងគ្រី) នៅឆ្នាំ១៩៧២ នៅពេលដែលខ្ញុំបានធ្វើដំណើរឆ្លងកាត់ទីនោះឆ្ពោះទៅទីក្រុងទីរ៉ាណា(ប្រទេសអាល់បានី) ដើម្បីទៅចូលរួមសមាជនៃយុវជនអាល់បានី ក្នុងនាមជាតំណាងយុវជនរណសិរ្សរួបរួមជាតិកម្ពុជា។

នៅរសៀលថ្ងៃដដែល ក្នុងនាមជាអ្នកបកប្រែ ខ្ញុំបានអមដំណើរគិលានុបដ្ឋាយិកានៃក្រសួងការបរទេសមួយរូបដែលត្រូវទៅសួរសុខទុក្ខភរិយាឯកអគ្គរដ្ឋទូត។ ឯកអគ្គរដ្ឋទូតនិងភរិយាបានទទួលគិលានុបដ្ឋាយិកាដោយសមគួរ ប៉ុន្តែគ្មានអ្វីលើសពីនេះទៀតទេ។ ប៉ុន្តែពួកគាត់មិនស្គាល់ខ្ញុំទាល់តែសោះ។ ខ្ញុំក៏មិនបានយកចិត្តទុកដាក់នឹងរឿងហ្នឹងពេកណាស់ណាដែរ ដោយខ្ញុំគិតថានេះប្រហែលជាទំនៀមទម្លាប់របស់ជនជាតិអាល់បានី ដែលគិតតែពីអ្នកដែលសំខាន់ប៉ុណ្ណោះនោះ។ ប៉ុន្តែឯកអគ្គរដ្ឋទូតបានចេះតែសម្លឹងមើលមកខ្ញុំ។ ចុងបញ្ចប់ គាត់ក៏ដាច់ចិត្តសួរខ្ញុំថា ៖ "អ្នកដែលខ្ញុំបានជួបព្រឹក

មិញជាមួយ លោក ខៀវ សំផន នោះ គឺជារូបលោកមែនទេ?” ដល់ខ្ញុំឆ្លើយថាមែន ទើបគាត់និយាយជាមួយខ្ញុំធម្មតា។ ក្រោយមក ឯកអគ្គរដ្ឋទូតក៏ធ្វើឱ្យយើងសង្កេតឃើញថា គាត់រស់នៅក្នុងលក្ខណៈខុសពីធម្មតា ជាជាងនិយាយថាក្នុងលក្ខណៈខុសពីគោលការណ៍នៃពិធីការ ក្នុងនាមខ្ញុំជាអ្នកបកប្រែដែលទទួលបន្ទុកពីប្រមុខរដ្ឋ ក្នុងការបំពេញមុខងារជាផ្លូវការនេះ។

ម៉្យាងទៀត ក្នុងនាមជាអនុប្រធានផ្នែកពិធីការ ខ្ញុំមានការទំនាក់ទំនងជាញឹកញាប់ខ្លះដែរជាមួយបេសកជននៃប្រទេសជាមិត្ត ដែលក្នុងចំណោមនោះក៏មានឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសយូហ្គោស្លាវី លោក Mihailo LOMPAR ផងដែរ។ ក៏ប៉ុន្តែ លោក Mihailo LOMPAR គឺជាជនជាតិម៉ុងតេណេហ្គ្រោទេ។ គាត់ទើបតែមកជំនួសអតីតឯកអគ្គរដ្ឋទូត លោក Milosovic។ មុនរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លោក Milosovic គឺជាអ្នកតំណាងរបស់ប្រទេសគាត់។ ក្រោយការរំដោះនៅឆ្នាំ១៩៧៥ គាត់បានមានបំណងត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីបញ្ចប់អាណត្តិរបស់គាត់។ គាត់ស្ថិតនៅក្នុងប្រភេទនៃអ្នកការទូតវិជ្ជាជីវៈ ដែលសមគួរ ប៉ុន្តែមិនសូវនិយាយស្តីច្រើនទេ រីឯឯកអគ្គរដ្ឋទូតថ្មីជាមនុស្សដែលសាមញ្ញ និយាយត្រង់ ហើយនិងរាក់ទាក់ទៀតផង។ បន្ទាប់ពីបានចាកចេញពីប្រទេសកម្ពុជាទៅ លោក Milosovic បានទទួលតំណែងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមស៊ែប៊ី។

ក្នុងពេលបំពេញវិជ្ជាជីវៈជាអ្នកការទូត ខ្ញុំមានឱកាសធ្វើដំណើរទៅកាន់ប្រទេសយូហ្គោស្លាវីជាច្រើនលើកច្រើនសា។ នៅឆ្នាំ១៩៧៣ ខ្ញុំបានអមដំណើរ សម្តេច នរោត្តម សីហនុ ដែលជាប្រមុខរដ្ឋនៅពេលនោះ ក្នុងដំណើរទស្សនកិច្ចជាផ្លូវរដ្ឋរបស់ទ្រង់ទៅកាន់ប្រទេសរបស់ទីតូ ដែលខ្ញុំមានកិត្តិយសបានជួប នៅ Brioni នៅសមុទ្រ Adriatique។ ប្រហែលដប់ឆ្នាំក្រោយ ខ្ញុំក៏បានត្រលប់ទៅទីនោះម្តងទៀតជាមួយ លោក ខៀវ សំផន និង លោក គាត ឈន់ ដើម្បីធ្វើកិច្ចការបន្តពីប្រមុខរដ្ឋរបស់យើង។ នៅឆ្នាំបន្ទាប់ ខ្ញុំបានទៅទីនោះទៀត ជាមួយ លោក ចាន់ យូរ៉ាន់ ពេញមួយខែមិថុនា ដើម្បីទៅចូលរួមសន្និសីទរបស់អង្គការសហប្រជាជាតិដើម្បីពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (CNUCED - UNCITAD)។ គឺនៅក្នុងអំឡុងពេលនៃការស្នាក់នៅនេះហើយ ដែលយើងអាចឱ្យតម្លៃលើបដិសណ្ឋារកិច្ច និងមិត្តភាពដ៏កក់ក្តៅនិងថ្លៃថ្លា ដែល លោក LOMPAR និងភរិយាដ៏មានមន្តស្នេហ៍របស់គាត់ និងអ្នកទទួលយើងជាជនជាតិយូហ្គោស្លាវីដទៃទៀត ដែលតែងតែមានចំពោះយើងជានិច្ច។

មានឧប្បត្តិហេតុមួយទៀតដែលគួរតែត្រូវលើកឡើងផងដែរ គឺកើតឡើងនៅរវាងចុងឆ្នាំ១៩៧៥។ ក្នុងនាមជាអនុប្រធានផ្នែកពិធីការ ខ្ញុំត្រូវបានក្រសួងចាត់តាំងឱ្យធ្វើការទំនាក់ទំនងដោយផ្ទាល់មាត់ ជាមួយឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ អំពីសំណើសុំជួបពិភាក្សាស្នើឡើងដោយឯកអគ្គរដ្ឋទូតថ្មី ដែលមានបំណងមកជួបឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសរបស់យើង ដើម្បីសម្តែងការគួរសម។

នៅតាមផ្លូវទៅស្ថានទូត ខ្ញុំបានជួបលេខាទីពីររបស់ស្ថានទូតកូរ៉េខាងជើង ដែលចេះនិយាយភាសាខ្មែរបានយ៉ាងថ្នឹក។ ខ្ញុំបានជម្រាបគាត់ពីអត្ថន័យនៃសារ ហើយបានស្នើសុំឱ្យគាត់នាំសារនេះទៅជម្រាបឯកអគ្គរដ្ឋទូតរបស់គាត់ផង។ អ្នកការទូតកូរ៉េបានស្តាប់ខ្ញុំ តែមិនឆ្លើយតបនឹងខ្ញុំវិញទេ។ គាត់គ្រាន់តែសម្លឹងមើលខ្ញុំពីក្បាលដល់ចុងជើង ជាមួយទឹកមុខដែលបង្ហាញនូវភាពជាធំ ដូចជាគ្មានសញ្ញាអ្វីមួយបញ្ជាក់ពីភាតរភាពបដិវត្តន៍ និងសាមគ្គីភាពវណ្ណៈអធនទាល់តែសោះ។ អាកប្បកិរិយារបស់គាត់មិនខុសអ្វីពីអាកប្បកិរិយារបស់សមភាគីកូរ៉េខាងត្បូងរបស់គាត់នោះទេ។ នៅពេលនោះខ្ញុំក៏បានដឹងថាខ្ញុំមិនបានគោរពតាមពិធីការ ដោយខ្ញុំមានបំណង “ធ្វើបដិវត្តន៍” លើការអនុវត្តផ្នែកការទូតនៃ “វណ្ណៈគហបតី”។ ដោយជនជាតិកូរ៉េនោះមិនទាន់បាននិយាយអ្វីផង ខ្ញុំក៏បានជម្រាបទៅគាត់ថា ខ្ញុំចង់ជួបអ្នកការទូតម្នាក់នៅស្ថានទូតរបស់គាត់ ដើម្បីជម្រាបអ្នកការទូតនោះអំពីសារផ្ទាល់មាត់របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ។ ដោយមិនអាចធ្វើអ្វីបានផ្សេងក្រៅពីយល់ព្រមតាមសំណើរបស់ខ្ញុំនោះ គាត់ក៏បានសូមឱ្យខ្ញុំតាមគាត់ទៅស្ថានទូត ដោយជិះកង់។ នៅស្ថានទូត ឯកអគ្គរដ្ឋទូតក៏បានមកទទួលខ្ញុំដោយផ្ទាល់ ដោយគោរពតាមគោលការណ៍នៃទម្លាប់ពិធីការ។

មានរឿងមួយទៀតដែលគួរតែរៀបរាប់ឱ្យដឹងផងដែរនោះ គឺថាខ្ញុំបានធ្វើការងារជាអ្នកបកប្រែឱ្យលោក អៀង សារី នៅពេលដែលលោកបានជួបពិភាក្សាគ្នាជាមួយឯកអគ្គរដ្ឋទូតនិងបេសកជននានានៃប្រទេសដែលបានទទួលការតែងតាំងនៅទីក្រុងភ្នំពេញ។ ការងារខ្ញុំមានការងាយស្រួលច្រើននៅពេលដែលការជួបពិភាក្សាធ្វើឡើងជាភាសាបារាំង។ ដោយឧបនាយករដ្ឋមន្ត្រីយើងចេះនិយាយភាសាបារាំង ខ្ញុំមិនចាំបាច់បកប្រែឱ្យគាត់នូវអ្វីដែលដៃគូសន្ទនារបស់គាត់បានមានប្រសាសន៍ជម្រាបគាត់នោះទេ។ ខ្ញុំគ្រាន់តែថាតាមប្រសាសន៍របស់ លោក អៀង សារី ដោយប្រើពាក្យពេជន៍ជាភាសាបារាំងឲ្យបានត្រឹមត្រូវល្អទៅកាន់ភ្ញៀវរបស់យើងតែប៉ុណ្ណោះ។

នៅព្រឹកមួយ នាខែកញ្ញា ឆ្នាំ១៩៧៥ យើងបានទទួលភ្ញៀវមួយរូប ដែលជាឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសអេហ្ស៊ីប។ ក្រៅពីភាសាអារ៉ាប់ គាត់អាចយល់តែភាសាបារាំងប៉ុណ្ណោះ។ ដូចទម្លាប់ ខ្ញុំក៏ធ្វើការងារជាអ្នកបកប្រែ។ បន្ទាប់ពីបានសម្តែងនូវការគួរសមជាធម្មតាដាក់គ្នាទៅវិញទៅមករួចមក យើងក៏បានចូលដល់ចំណុចសំខាន់នៃប្រធានបទ។ គឺនៅពេលនោះហើយដែលអ្វីៗមានការស្មុគស្មាញ។ ឯកអគ្គរដ្ឋទូតប្រទេសអេហ្ស៊ីបតែងតែឱ្យខ្ញុំនិយាយឡើងវិញគ្រប់ពេលនូវអ្វីដែលលោក អៀង សារី បានមានប្រសាសន៍ប្រាប់គាត់។ នៅក្នុងចិត្តរបស់ខ្ញុំ ខ្ញុំមានការកោតសរសើរចំពោះភាពប្រុងប្រយ័ត្នប្រកបដោយស្មារតីស្នេហាមាតុភូមិនៃជនជាតិអេហ្ស៊ីប។ ប៉ុន្តែនៅពេលមួយនៃកិច្ចពិភាក្សាគ្នានោះ ឯកអគ្គរដ្ឋទូតបានលើកឡើងពីបញ្ហាដដែលៗដែលគាត់បាននិយាយរួចមកហើយ។ នៅពេលនោះ ខ្ញុំក៏ចាប់ផ្តើមសួរខ្លួនឯងថា នេះមកពីភាសាបារាំងរបស់ខ្ញុំមិនច្បាស់ ឬមួយក៏ឯកអគ្គរដ្ឋទូត...។ ដោយសារការពិភាក្សាបានប្រើពេលអស់ជាងបីម៉ោងទៅហើយនោះ លោក អៀង សារី ដែលទំនងជាមួម៉ៅ បាននិយាយខ្មែរមកកាន់ខ្ញុំថា ៖ "បើអញ្ចឹង និយាយភាសាបារាំងជាមួយគាត់មើ! បោយ[1]!"។ នៅពេលនោះ លោក អៀង សារី ក៏បាននិយាយភាសាបារាំងតាមបែបសាមញ្ញជាមួយអ្នកការទូតអេហ្ស៊ីបដោយខ្លួនគាត់ផ្ទាល់។ អ្នកការទូតមើលទៅហាក់ដូចជាមានការពេញចិត្ត។ និយាយទៅ គាត់លែងឱ្យខ្ញុំនិយាយឡើងវិញនូវអ្វីដែលខ្ញុំបានបកប្រែឱ្យគាត់នោះទៀតហើយ។

ទំនាក់ទំនងរបស់យើងជាមួយប្រទេសចិន វៀតណាម និងកូរ៉េខាងជើង ធ្វើឡើងជាពិសេសសក្នុងកំរិតបក្សនិងបក្ស។ ដូច្នេះ ពួកគេមិនត្រូវការជំនួយពីខ្ញុំនោះទេ។

ម្យ៉ាងទៀត អ្នកតំណាងបក្សនិងចលនាបដិវត្តន៍នីមួយៗ ដែលធ្វើសកម្មភាពដោយលួចលាក់នៅក្នុងប្រទេសរបស់ពួកគេ ក៏មានវត្តមានផងដែរនៅលើទឹកដីនៃប្រទេសកម្ពុជា។ នៅក្នុងចំណោមអ្នកទាំងនោះ មានអ្នកមកពីបក្សកុម្មុយនីស្តថៃ បក្សកុម្មុយនីស្តឥណ្ឌូណេស៊ី រណសិរ្សរំដោះជាតិទីម័រខាងកើត និងពីសមាជទ្វីបអាហ្វ្រិក (PAC)។ វត្តមានរបស់ពួកគេនៅកម្ពុជាបានធ្វើឡើងជាសម្ងាត់ និងត្រូវបានគេដឹងតែនៅឆ្នាំ១៩៧៩ប៉ុណ្ណោះ គឺបន្ទាប់ពីវៀតណាមបានវាយលុកចូល ដោយនៅពេលនោះ អ្នកទាំងនោះបានរត់គេចទៅជាយព្រំដែនខ្មែរ-ថៃ ជាមួយជនភៀសខ្លួនកម្ពុជា។ ថ្ងៃទី១១ ខែ

---

[1] ពាក្យបារាំងដែលប្រើដោយអ្នកបម្រើដែលជាម្ចាស់ស្រុក ឬដោយអ្នកបម្រើនៅតាមហាងកាហ្វេនៅសម័យអាណានិគម។

កក្កដា ឆ្នាំ១៩៧៩ កូនស្រីខ្ញុំពីរនាក់គឺ ណារ៉ែន និងសុខា ហើយនិងម្ដាយរបស់ពួកគេ បានធ្វើដំណើរពីទីក្រុងបាងកកមកទីក្រុងប៉េកាំង ជាមួយនឹងសកម្មជននៃបក្សកុម្មុយនីស្ដឥណ្ឌូនេស៊ី ដែលអ្នកទាំងនោះក៏មានកាន់លិខិតឆ្លងដែនកម្ពុជាផងដែរ។

ការផ្ដាច់ទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យជាមួយភាគីនិងចលនានានា ធ្វើឡើងតែក្រោយពីឆ្នាំ១៩៧៩តែប៉ុណ្ណោះ ពីព្រោះនៅក្នុងការវាយប្រយុទ្ធជាថ្មីរបស់យើង យើងត្រូវការការគាំទ្រជាចាំបាច់ពីសំណាក់ប្រទេសជាសមាជិកអាស៊ាន គឺប្រទេសថៃនិងប្រទេសឥណ្ឌូនេស៊ី។ ម៉្យាងទៀត តួនាទីថ្មីរបស់យើងបានទទួលនូវការយោគយល់ទាំងស្រុង ពីសំណាក់រណសិរ្សបដិវត្តន៍ដើម្បីឯករាជ្យទីម័រខាងកើត (Fretilin)។

## ៣. ជំនួបជាមួយ ប៉ុល ពត

ថ្វីតត្បិតតែយើងផ្ដល់សារៈសំខាន់ទៅលើទំនាក់ទំនងរបស់យើងជាមួយបក្សម៉ាកលេនីននៅទ្វីបអឺរ៉ុប និងនៅទ្វីបអាមេរិកខាងត្បូងក៏ដោយ ក៏ប៉ុន្តែទន្ទឹមនឹងនោះ យើងក៏មិនបានព្រងើយកន្ដើយក្នុងការបង្កើននូវទំនាក់ទំនងរបស់យើង ជាពិសេសជាមួយនឹងបក្សនិងចលនានៃប្រទេសនិយាយភាសាអង់គ្លេសនៅទ្វីបអាស៊ី និងនៅទ្វីបអាហ្វ្រិកផងដែរ។

ជួន ប្រាសិទ្ធ បានធ្វើជាអ្នកបកប្រែ នៅក្នុងកិច្ចពិភាក្សារវាងអ្នកដឹកនាំសំខាន់ៗរបស់យើង ជាពិសេស លោក ប៉ុល ពត និង លោក អៀង សារី ជាមួយនឹងអ្នកតំណាងបក្សនិងចលនានៃប្រទេសនិយាយភាសាអង់គ្លេសនៅទ្វីបអាស៊ី និងនៅទ្វីបអាហ្វ្រិក។

ដូច គាត ឈន់ ដែរ ប្រាសិទ្ធ គឺជាអ្នកចាត់ចែងម្នាក់នៅក្នុងក្រសួង ទោះបីជាគាត់មិនមានឋានៈជាផ្លូវការណាមួយក៏ដោយ។ គាត់ជាមនុស្សដែលធ្វើអ្វីៗបានទាំងអស់ ពីព្រោះគាត់មិនដែលបដិសេធចំពោះការងារណាមួយដែលគេប្រគល់ឱ្យគាត់នោះទេ។ ក្នុងនាមជាមិត្តផ្ទាល់ខ្លួនរបស់ ប៉ុល ពត និង អៀង សារី គាត់មានភក្ដីភាពនិងស្មោះស្ម័គ្រចំពោះពួកគេណាស់។ គឺប្រាកដណាស់ ដោយសារតែមិត្តភាពនេះហើយដែលបានជួយជីវិតលោក ប្រាសិទ្ធ ពីព្រោះថាបន្ទាប់ពីសាស្ត្រាចារ្យជនជាតិអង់គ្លេស Malcolm CIALDWELL ត្រូវបានគេធ្វើឃាត នៅខែធ្នូ ឆ្នាំ១៩៧៨ មក ស្រាប់តែមានលេចឈ្មោះ ប្រាសិទ្ធ នៅក្នុងបញ្ជីជនសង្ស័យនៃគណៈកម្មាធិការសន្តិសុខ ជាមួយគ្នានឹង ស្វ ហុង

និង ភី ភួន ហៅ ជាម ដែរ ដែលនៅពេលនោះ សុន សេន ជាអ្នកដឹកនាំគណៈកម្មាធិការសន្តិសុខនេះ។

ខ្ញុំកម្រត្រូវគេចាត់តាំងឱ្យធ្វើជាអ្នកបកប្រែឱ្យ ប៉ុល ពត ណាស់។ ក៏ប៉ុន្តែ នៅខែកញ្ញា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានគេឱ្យធ្វើជាអ្នកបកប្រែឱ្យគាត់ នៅពេលដែលគាត់ទទួលគណៈប្រតិភូស្ត្រីវៀតណាម។ ជាដំបូង គាត់បានសួរពីសុខភាពរបស់ខ្ញុំចាប់តាំងពីខ្ញុំមកដល់ភ្នំពេញ។ បន្ទាប់មក គាត់បានសួរពីការងារខ្ញុំ។ ក្នុងអំឡុងពេលជួបពិភាក្សាជាមួយភ្ញៀវជនជាតិវៀតណាមរបស់យើង ខ្ញុំបានជួបការលំបាកខ្លះៗ ឧទាហរណ៍ដូចជាការរកពាក្យឱ្យបានត្រឹមត្រូវ។ លោកស្រី អៀង ធីរិទ្ធ ដែលបានចូលរួមនៅក្នុងជំនួបនោះផងដែរ បានជួយខ្ញុំជាច្រើនលើកច្រើនសា។ ប៉ុន្តែ ប៉ុល ពត បានធ្វើសញ្ញាឱ្យគាត់ ដើម្បីទុកឱ្យខ្ញុំធ្វើការងារខ្ញុំដោយខ្លួនឯង។

ខ្ញុំអាចនិយាយបានថា ការជួបគ្នាលើកទីមួយនេះបានធ្វើឱ្យខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ខ្ញុំយល់ឃើញថា ប៉ុល ពត ជាមនុស្សដែលមានជំនឿចិត្តយ៉ាងខ្លាំងលើខ្លួនឯង ហើយក៏ជាមនុស្សម្នាក់ដែលសាមញ្ញខុសពីធម្មតា។ ឧទាហរណ៍ដូចជាពេលគាត់ឃើញអ្នក គាត់មិនចាំឱ្យអ្នកទៅដើរទៅរកគាត់ទេ។ គាត់តែងតែដើរមករកអ្នកដើម្បីគោរពអ្នកមុនជានិច្ច។ ទាក់ទងនឹងចំនុចនេះ គាត់បាននាំយកនូវអ្វីដែលថ្មីខ្លះៗដល់ការអនុវត្តពិធីការទូត។ ឧទាហរណ៍នៅឆ្នាំ១៩៧៦ នៅពេលមានទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រមុខរដ្ឋបរទេសទីមួយនៅប្រទេសកម្ពុជា ពោលគឺដំណើរទស្សនកិច្ចរបស់លោក Ne Win ប្រធានាធិបតីនៃប្រទេសភូមា គឺ ប៉ុល ពត ខ្លួនឯងដែលបានសុំទៅធ្វើគារវកិច្ចប្រធានាធិបតីដល់គេហដ្ឋានសម្រាប់ភ្ញៀវមុន។ ដូច្នេះនេះគឺជាការមិនគោរពតាមពិធីការបែបបុរាណ ដែលតម្រូវឱ្យភ្ញៀវទៅជួបម្ចាស់ផ្ទះ ដើម្បីសម្តែងការគួរសម ជាជាងឱ្យម្ចាស់ផ្ទះមកជួបភ្ញៀវ។ ប៉ុល ពត បានលើកមូលហេតុដែលគាត់សម្រេចធ្វើយ៉ាងនេះថា ចំពោះគាត់ វាជាការមួយសមរម្យជាងក្នុងការដែលអ្នកដែលមានវ័យក្មេងជាងទៅសម្តែងការគួរសមដល់ភ្ញៀវដ៏មានកិត្តិនាមរបស់ខ្លួន។

ខ្ញុំសូមបញ្ជាក់ទាក់ទងនឹងរឿងតូចតាចមួយថា ប្រធានាធិបតីភូមាពិតជាមានការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ហើយគាត់ពិតជាស្នើសុំយកអង្ករភូមាមួយបាវធំ ហើយនិងសម្ភារៈធ្វើម្ហូបទាំងអស់ រួមទាំងគ្រឿងទេសនិងគ្រឿងកំប៉ុងមកជាមួយគាត់ផងដែរ។

អ្នកដឹកនាំកម្ពុជាបានទទួលយកសកម្មភាពភូមាដោយការអត់ធ្មត់។ ខ្ញុំគិតថា ប៉ុល ពត លួចសរសើរ Ne Win នៅក្នុងចិត្ត ដែលទុកចិត្តតែទៅលើធនធាននិងមធ្យោបាយផ្ទាល់របស់ខ្លួនតែប៉ុណ្ណោះ។ នេះគឺជាចំណុចដែល ប៉ុល ពត និង Ne Win ដូចគ្នាយ៉ាងចំឡែក ពីព្រោះ ប៉ុល ពត ទុកចិត្តតែទៅលើសមត្ថភាពនិងទេពកោសល្យរបស់ខ្លួនតែប៉ុណ្ណោះ។ ប្រាកដណាស់ ដោយសារតែការជឿជាក់លើខ្លួនឯងជ្រុលហួសហេតុរបស់គាត់នេះហើយ ដែលជាប្រភពនៃការបរាជ័យរបស់គាត់។

## IV. បុគ្គលអមតៈផ្ញើមទីពីរ

អស់រយៈពេលជាងពីរឆ្នាំហើយដែលខ្ញុំបានមករស់នៅមន្ទីរ ប-១ ។ ក្នុងនាមជាសមាជិកពេញសិទ្ធិបក្សតាំងពីឆ្នាំ១៩៧១ ខ្ញុំត្រូវបានគេហៅឱ្យទៅបម្រើការងារនៅគ្រប់នាយកដ្ឋានទាំងអស់នៃក្រសួង ។ ជាបន្តបន្ទាប់ ខ្ញុំក៏ត្រូវបានគេចាត់តាំងជាប្រធាននាយកដ្ឋានអឺរ៉ុប ប្រធាននាយកដ្ឋានអាស៊ីអាគ្នេយ៍ អនុប្រធានលេខាធិការដ្ឋាន អនុប្រធានផ្នែកពិធីការ និងអនុប្រធាននាយកដ្ឋាននយោបាយទូទៅ។ នៅនាយកដ្ឋានទាំងអស់នេះ ជាពិសេសនៅរដ្ឋលេខាធិការដ្ឋាន និងផ្នែកពិធីការ គឺខ្ញុំទទួលខុសត្រូវការងារច្រើនជាងគេ រីឯថ្នាក់លើរបស់ខ្ញុំគ្រាន់តែបំពេញមុខងារកិត្តិយសរបស់គាត់ប៉ុណ្ណោះ។ ហេតុនេះហើយបានជា គាត ឈន់ ដែលនិយាយរាងមែនទែនបន្តិច រាងលេងសើចបន្តិច បានផ្តល់ឋានៈ"បុគ្គលផ្ញើមទីពីរ"ឱ្យខ្ញុំ ហើយគាត់ក៏បានបញ្ចុះបញ្ចូលឱ្យខ្ញុំមានបំណងធ្វើជា "បុគ្គលផ្ញើមទីមួយ"។

ប៉ុន្តែការដាក់ងារយ៉ាងនេះហាក់ដូចជាមានហេតុផល ពីព្រោះថាជាច្រើនលើកហើយដែលឋានៈជាផ្លូវការរបស់ខ្ញុំអាចឱ្យខ្ញុំកាន់តួនាទីយ៉ាងពេញលេញ ក្នុងនាមជាសិទ្ធិរបស់ខ្ញុំ។ ក៏ប៉ុន្តែ ការពិតមិនដូច្នោះនោះទេ។ ខ្ញុំលើកឧទាហរណ៍ពីរ គ្រប់គ្រាន់ហើយ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ គណៈប្រតិភូការទូតនៃប្រទេសរូម៉ានីមួយក្រុមបានមកដល់ទីក្រុងភ្នំពេញ។ ក្នុងនាមជាប្រធាននាយកដ្ឋានអឺរ៉ុបនៃក្រសួងការបរទេស គឺខ្ញុំត្រូវមានសិទ្ធិនឹងទៅទទួលភ្ញៀវរូម៉ានីរបស់យើងជាផ្លូវការ។ ប៉ុន្តែ លោក អៀង សារី បានសម្រេចផ្សេងពីនេះទៅវិញ។ ខ្ញុំត្រូវបានគេតែងតាំងជាអនុប្រធាន និងជាអ្នកបកប្រែឱ្យ មាឃ ទូច (ខែម) ទៅវិញ ដែលក្រោយមក គាត់បានធ្វើជាឯកអគ្គរដ្ឋទូតនៅប្រទេសឡាវ មុនត្រូវគេសម្លាប់នៅទួលស្លែង ក្នុងឆ្នាំ១៩៧៨។ បន្ទាប់ពីអ្នក

តំណាងប្រទេសរូម៉ានីត្រឡប់ទៅវិញ នៅពេលប្រជុំការងារមួយ មាឃ ទូច បានរិះគន់ខ្ញុំពីរដង ដោយថាខ្ញុំមានបំណងដើរតួនាទីជាប្រធានជាជាងដើរតួនាទីជាអ្នកបកប្រែ។

ឧទាហរណ៍មួយទៀត គឺនៅឆ្នាំ១៩៧៨។ គណៈប្រតិភូអ្នកកាសែតនៃប្រទេសយូហ្គោស្លាវីមួយក្រុម បានមកធ្វើទស្សនកិច្ចការងារនៅប្រទេសកម្ពុជា។ ក្នុងនាមជាអ្នកទទួលខុសត្រូវនៃនាយកដ្ឋានសារព័ត៌មាននិងព័ត៌មាន ខ្ញុំត្រូវចាត់តាំងឱ្យទៅអមដំណើរគណៈប្រតិភូមួយក្រុមនោះ ហើយនេះគឺអ្វីដែលគេបានសម្រេចដែរ។ ក៏ប៉ុន្តែ នៅនាទីចុងក្រោយ នី កន ប្រធានពិធីការ បានមកជំនួសកន្លែងខ្ញុំទៅវិញ ហើយខ្ញុំក៏ត្រូវបានគេឱ្យធ្វើជាអ្នកបកប្រែឱ្យគាត់។ ប៉ុន្តែ ខ្ញុំមិនអន់ចិត្តនឹងរឿងនេះទេ ហើយថែមទាំងមានអារម្មណ៍ធូរស្បើយទៀតផង ពីព្រោះថា នៅឆ្នាំ១៩៧៨ នៅមន្ទីរ ប-១ បរិយាកាសមិនមានភាពស្ងប់ស្ងៀមដូចមុនទៀតទេ។ ខ្ញុំមានអារម្មណ៍តានតឹងនៅក្នុងខ្លួន។ លោក អៀង សារី ខ្លួនឯងក៏មានអារម្មណ៍ខ្វល់ខ្វាយម៉េចមិនដឹងដែរ។

## ៥. ការប្រកាសជាផ្លូវការនៃបក្សកុម្មុយនីស្តកម្ពុជា (PCK)

កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ គណៈប្រតិភូបក្សកុម្មុយនីស្តកម្ពុជា ដែលដឹកនាំដោយផ្ទាល់ដោយ ប៉ុល ពត បានធ្វើដំណើរទស្សនកិច្ចជាផ្លូវការមួយនៅសាធារណរដ្ឋប្រជាមានិតចិន និងនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។ នេះជាឱកាសសម្រាប់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ក្នុងការប្រកាសពីអត្ថិភាពជាផ្លូវការនៃបក្សកុម្មុយនីស្តកម្ពុជា ដែលសមាជនៃការបង្កើតបក្សត្រូវបានធ្វើឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ នៅទីក្រុងភ្នំពេញ។

ក្នុងរយៈពេលពីរយប់ពីរថ្ងៃបន្តបន្ទាប់គ្នា គ្រប់បុគ្គលិកទាំងអស់នៃក្រសួងការបរទេសត្រូវបានគេហៅឱ្យមកជួបជុំគ្នាដើម្បីផ្ញើចេញទៅក្រៅ និងដើម្បីបកប្រែឯកសារមួយទាក់ទងនឹងប្រវត្តិនៃបក្សដែលមានចំណងជើងថា “សេចក្ដីប្រកាសជាឱឡារិកពីអត្ថិភាពជាផ្លូវការនៃបក្សកុម្មុយនីស្តកម្ពុជា” ជាភាសាបារាំងនិងភាសាអង់គ្លេស។ យើងក៏ត្រូវតាក់តែងសុន្ទរកថាដែល ប៉ុល ពត នឹងត្រូវថ្លែងនៅប្រទេសចិន និងនៅប្រទេសកូរ៉េខាងជើងផងដែរ។

គឺនៅកំឡុងពេលនៃទស្សនកិច្ចនេះហើយ ដែលពិភពលោកកំណត់បានពីអត្តសញ្ញាណរបស់ ប៉ុល ពត ថាជា សាឡុត ស អតីតនិស្សិតផ្នែកវិទ្យុនិងអគ្គិសនី នៅទីក្រុងប៉ារីស និងជាអតីតសាស្ត្រាចារ្យភាសាបារាំង នៅអនុវិទ្យាល័យឯកជនចំរើនវិជ្ជា នៅទីក្រុងភ្នំពេញ។

## ៦. ថ្នាក់ដឹកនាំនាយកដ្ឋានសារព័ត៌មាននិងព័ត៌មាននៃក្រសួង

ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យគឺជាបណ្តុំនៃអគារជាច្រើន ក្នុងនោះមានអគារមេដែលគេហៅ "ផ្ទះកោងកញ្ចក់" ហើយដែលពីមុន គឺជាអតីតអាសនៈនៃទីស្តីការគណៈរដ្ឋមន្ត្រី។ នៅជុំវិញអគារមេ មានផ្ទះវីឡាជាច្រើន។

កម្មាភិបាលជាន់ខ្ពស់ស្នាក់នៅក្នុងផ្ទះវីឡាដោយឡែក ចំណែកបុគ្គលិកធម្មតាស្នាក់នៅក្នុងផ្ទះល្វែង។ ម្យ៉ាងទៀត យើងផ្លាស់ប្តូរកន្លែងស្នាក់នៅជាញឹកញាប់ ដោយមូលហេតុចិត្តសាស្ត្រនិងមនោគមវិជ្ជា គឺគ្មានទាក់ទងខាងផ្នែកសម្ភារៈនោះទេ។ ការផ្លាស់ប្តូរទីកន្លែងជាញឹកញាប់នេះ គឺជាមធ្យោបាយមួយដើម្បីកុំឱ្យអ្នកស្នាក់នៅមានទម្លាប់ក្នុងការដែលមានអ្វីមួយជាប់លាប់ និងទម្លាប់មានផាសុកភាព។ រាល់ពេលដែលប្តូរកន្លែងស្នាក់នៅ ខ្ញុំតែងតែមានអ្នកជិតខាងថ្មីម្នាក់ជានិច្ច។ ដំបូង គឺ គ្រិន លាន ជាវិស្វករមកពីទីក្រុងម៉ូស្គូ និងជាអតីតប្រធានខុទ្ទកាល័យ សម្តេច ប៉ែន នុត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNC)។ បន្ទាប់មក គឺ តូច ខាំឿន បណ្ឌិតខាងគណិតវិទ្យា មកពីសកលវិទ្យាល័យប៉ារីស ប្រធានសមាគមនិស្សិតខ្មែរនៅបារាំងមុនខ្ញុំ អតីតឯកអគ្គរដ្ឋទូតនៅប្រទេសចិន និងជាប្អូនប្រុសរបស់ តូច ភឿន រដ្ឋមន្ត្រីក្រសួងសាធារណការនៃកម្ពុជាប្រជាធិបតេយ្យ និងជាអ្នកដែលបានពាក់ព័ន្ធក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារ នៅឆ្នាំ១៩៧៦ ជាមួយនឹង កុយ ធួន ហើយដែលត្រូវបានគេសម្លាប់។ ជាមួយ គាត ឈន់ យើងបានបង្កើតក្រុមដែលមានគ្នាបីនាក់ និងដែលនៅជាមួយគ្នារហូតមក គឺចាប់តាំងពីនៅអនុវិទ្យាល័យព្រះសីហនុ នៅខេត្តកំពង់ចាម រហូតដល់បុរីសកលវិទ្យាល័យទីក្រុងប៉ារីស។ អ្នកជិតខាងខ្ញុំចុងក្រោយ គ្មានអ្នកណាក្រៅពី នី កន ប្អូនប្រុសរបស់ សុន សេន នោះទេ។ សុន សេន គឺជាអតីតគ្រូបង្រៀន អតីតប្រធានពិធីការនៃក្រសួងការបរទេស ឧត្តមសេនីយ៍ម្នាក់របស់ខ្មែរក្រហម ហើយបច្ចុប្បន្ននេះ ជាឧត្តមសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងជាទីប្រឹក្សាក្រសួងការពារជាតិ នៅទីក្រុងភ្នំពេញ។

បន្ទាប់ពីកាន់តួនាទីទទួលការខុសត្រូវនៅគ្រប់នាយកដ្ឋានទាំងអស់នៃក្រសួង ចុងបញ្ចប់ នៅខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវបានគេតែងតាំងជាអគ្គនាយកនៃនាយកដ្ឋានសារព័ត៌មាននិងព័ត៌មាន។ ក្នុងចំណោមអ្នកបញ្ញវន្តដែលមកពីប្រទេសក្រៅ មានតែខ្ញុំម្នាក់គត់ដែលមានតួនាទីក្នុងថ្នាក់ដឹកនាំនាយកដ្ឋានដ៏សំខាន់មួយនៅក្នុងក្រសួង។ ការតម្លើងឋានន្តរសក្តិនេះបង្ហាញនូវការទុកចិត្តមកលើខ្ញុំពីសំណាក់អ្នកដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ ដែលនៅពេលនោះប្រធានផ្ទាល់របស់ខ្ញុំគឺ លោក អៀង សារី និងអ្នកដឹកនាំកំពូល គឺ លោក ប៉ុល ពត ពីព្រោះថារាល់ការសម្រេចទាក់ទងនឹងរឿងខ្ញុំត្រូវមានការយល់ព្រមពីលោក ប៉ុល ពត។

ក្រៅពីតួនាទីដឹកនាំនាយកដ្ឋានសារព័ត៌មាននិងព័ត៌មាននៃក្រសួង ខ្ញុំក៏មានតួនាទីជាអគ្គនាយកនៃទីភ្នាក់ងារសារព័ត៌មានកម្ពុជា និងជាអ្នកទទួលខុសត្រូវនៃការចេញផ្សាយ"សម្លេងនៃកម្ពុជាប្រជាធិបតេយ្យ" ជាភាសាបរទេសផងដែរ។ ម៉្យាងទៀត ខ្ញុំក៏ត្រូវបានគេចាត់តាំងឱ្យរៀបចំឲ្យបុគ្គលិកទាំងអស់នៃក្រសួងស្តាប់រួមគ្នានូវកម្មវិធី "អប់រំនយោបាយ"នៃ"សម្លេងកម្ពុជាប្រជាធិបតេយ្យ" ដែលធ្វើឡើងជារៀងរាល់ថ្ងៃ នៅម៉ោងប្រាំព្រឹក។

ការងារដែលត្រូវការពេលគិតច្រើនជាងគេ ហើយនិងគួរឱ្យធុញទ្រាន់ជាងគេ គឺការកែការបកប្រែ ហើយនិងការថតជាខ្សែអាត់នូវព័ត៌មានជាភាសាបរទេស។ ការបកប្រែជាភាសាបារាំង ភាសាអង់គ្លេស និងភាសាវៀតណាម មិនមានចោទជាបញ្ហាអីនោះទេ ក៏ប៉ុន្តែការបកប្រែជាភាសាចិនមានការលំបាកច្រើនដែលមិនអាចចៀសបាន ពីព្រោះថាអ្នកដែលជាសហការី សហការិនីរបស់ខ្ញុំដែលចេះភាសាចិនច្បាស់ មិនចេះភាសាយើងបានល្អនោះទេ ហើយផ្ទុយទៅវិញ អ្នកដែលចេះភាសាយើងច្បាស់ តែបែរជាមិនចេះភាសាចិនបានល្អទៅវិញ។ ហេតុនេះហើយបានជាយើងត្រូវសុំជំនួយពីអ្នកជំនាញនៅស្ថានទូតចិន។ ប៉ុន្តែអត្ថបទដែលកែហើយត្រូវបានបញ្ជូនមកឱ្យយើងវិញតែនៅវេលាម៉ោងពីរព្រឹកប៉ុណ្ណោះ។ ដូច្នេះ ខ្សែអាត់ថតចប់ត្រឹមពេលល្មម គឺថានៅវេលាម៉ោងបួនកន្លះ ហើយបន្ទាប់មកខ្សែអាត់នោះត្រូវគេបញ្ជូនទៅស្ថានីយ៍វិទ្យុស្ទឹងមានជ័យ ដែលត្រូវចាប់ផ្តើមផ្សាយនៅម៉ោងប្រាំ។

ភាពលម្អិតដែលគួឱ្យសង្រេងបន្តិចនិងគួរឱ្យចង់សើចបន្តិច គឺថាដោយនៅពេលថតខ្សែអាត់ មានតែអ្នកផ្សាយជានារី ហើយមានតែខ្ញុំម្នាក់ដែលជាប្រុស ខ្ញុំក៏បានសុំឱ្យប្រពន្ធខ្ញុំ ឡូរ៉ង់ ពិច មកកំដរខ្ញុំជា

រៀងរាល់យប់។ ពេលនោះ នាងគេងនៅលើគ្រែមួយរបស់មន្ទីរ។ នាងមានទម្ងន់ជាងបួនខែមកហើយ។

នៅក្នុងចំណោមសហការីដែលស្និទ្ធស្នាលជាងគេរបស់ខ្ញុំ មាន លោក ឡុង ណូរិន បណ្ឌិតខាងកីឡា នៅមហាវិទ្យាល័យឆាល នៅទីក្រុងប្រាក ដែលក្រោយមកធ្វើជាអគ្គលេខានៃចលនារួបរួមជាតិប្រជាធិបតេយ្យ (MUND) លោក ម៉ក់ បេន បណ្ឌិតខាងសេដ្ឋកិច្ចនៃសកលវិទ្យាល័យប៉ារីស និងជាអ្នកនាំពាក្យនៃកម្ពុជាប្រជាធិបតេយ្យ នៅក្នុងកិច្ចពិភាក្សាដើម្បីសន្តិភាព នៅទីក្រុងប៉ារីស ឆ្នាំ ១៩៩១ និង លោក ង៉ោ ហាក់ទាម ស្ថាបត្យករ និងជាអតីតអ្នកតំណាងអចិន្ត្រៃយ៍នៃកម្ពុជាប្រជាធិបតេយ្យប្រចាំនៅអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ។ ខ្ញុំមិនអាចបញ្ចប់បញ្ជីឈ្មោះ ដោយមិនរាប់បញ្ចូល ឃួន ស៊ីឃន លេខាផ្ទាល់របស់ខ្ញុំបានឡើយ។ គាត់ជាមនុស្សឧស្សាហ៍ព្យាយាមក្នុងការងារ ចេះជួយទុក្ខធុរៈអ្នកដទៃ និងមានចិត្តអត់ធ្មត់ចំពោះរាល់ការលំបាក។ បន្ថែមលើនេះ ខ្ញុំសូមរាប់បញ្ចូលជាពិសេស ឡូរ៉ង់ ពិច ដែលជាភរិយាខ្ញុំ។ ទោះបីជាឡូរ៉ង់ធ្វើការនៅក្រោមឱវាទលេខាធិការដ្ឋានរបស់ក្រសួង ដែលមានភរិយារបស់លោក ប៉េះ ប៊ុនរ៉េត ហៅ សូ សែ ជាអ្នកគ្រប់គ្រង ហើយដែលឡូរ៉ង់ត្រូវជាមិត្តភក្តិរបស់គាត់ផ្ទាល់ក៏ដោយ ក៏ឡូរ៉ង់បានជួយខ្ញុំយ៉ាងច្រើនក្នុងការងាររបស់ខ្ញុំ តាមរយៈការផ្តល់ដំបូន្មានដ៏ល្អៗ ក៏ដូចជាតាមរយៈទឹកចិត្តគាត់ដែលចង់ជួយខ្ញុំ។ ជាពិសេស ឡូរ៉ង់មានសមត្ថភាពបកប្រែភាសាពីខ្មែរទៅបារាំង និង អង់គ្លេស គ្មានគូប្រៀប។ សមត្ថភាពវាយអង្គុលីលេខរបស់គាត់ក៏គ្មានគូផ្ទឹមដែរ។

នៅក្រសួង យើងចាប់ផ្តើមធ្វើសកម្មភាពនៅម៉ោង៥ព្រឹក ដោយប្រមូលផ្តុំគ្នាស្តាប់វិទ្យុ "សម្លេងកម្ពុជាប្រជាធិបតេយ្យ"។ នៅប្រហែលម៉ោង៦ យើងប្រណាំងប្រជែងគ្នាធ្វើពលកម្មយ៉ាងសស្រាក់សស្រាំ ជាពិសេសក្នុងការស្រោចស្រពដំណាំ និងបន្លែបង្កា។ បន្ទាប់មក នៅម៉ោង៧ ក្រោយពីស្រស់ស្រូបអាហារពេលព្រឹក និងគោរពទង់ជាតិរួចហើយ យើងចាប់ផ្តើមធ្វើការនៅការិយាល័យ។ នៅការិល័យ ការងារចម្បងរបស់យើង គឺបកប្រែឯកសារ ឬអត្ថបទជាភាសាបរទេសមកជាភាសាខ្មែរសម្រាប់ប្រគល់ជូនអ្នកដឹកនាំរបស់យើង និងតាក់តែងលិខិត និងអត្ថបទសម្រាប់វិទ្យុ "សម្លេងកម្ពុជាប្រជាធិបតេយ្យ" ឬសម្រាប់ទស្សនាវដ្តី "បដិវត្តន៍" ដែលជាសារពត៌មានសរសេរជាភាសាជាតិតែមួយគត់។ នៅពេលដែលអ្នកដឹកនាំ ឬកម្មាភិបាលយើងជួបសំណេះសំណាលជាមួយអ្នកតំណាងនៃប្រទេសបរទេស យើងក៏ធ្វើការងារជាអ្នកបកប្រែផ្ទាល់មាត់ផងដែរ។ ជាមួយនឹង ឡុង ណូរិន ខ្ញុំក៏ទទួលបន្ទុកផងដែរខាងតាមការពាររថយន្តដឹកសំបុត្រឬសម្ភារៈទូតដែលបញ្ជូនម្តងក្នុង

មួយសប្តាហ៍ ពោលគឺរៀងរាល់ថ្ងៃសៅរ៍ ទៅកាន់ស្ថានទូតយើងប្រចាំនៅប្រទេសចិន ដែលមានតួនាទីចែកចាយឯកសារនៅបរទេស។

ក្រៅពីការងារតែងនិពន្ធ បកប្រែលើក្រដាស និងដោយផ្ទាល់មាត់ យើងត្រូវស៊ូទ្រាំនឹងវគ្គប្រជុំរៀនសូត្រ និងវគ្គជីវទស្សន៍នយោបាយ និងមនោគមវិជ្ជា ដែលមានរយៈពេលយូរៗ។ ដោយឡែក នៅរាល់វគ្គរៀនសូត្រ ខ្ញុំឆ្លៀតសម្ងំគេងពីរបីនាទីដើម្បីយកកម្លាំង ដោយសារបន្ទុកការងារធ្ងន់ធ្ងរពេក។

នៅពេលប្រជុំការងារ គេនិយាយសង្កត់ធ្ងន់ទៅលើការអនុវត្តផែនការដែលបានកំណត់នាពេលកន្លងមក និងទៅលើការដកបទពិសោធន៍ល្អៗ។ បន្ទាប់មកទៀត គេគ្រោងទុកជាមុននូវការងារដែលត្រូវបំពេញក្នុងរយៈពេលបីថ្ងៃខាងមុខ។ ជាទូទៅ ការប្រជុំការងារនេះមិនប្រើពេលលើសពីមួយម៉ោងទេ ហើយក៏មិនសូវមានការពិភាក្សាគ្នាខ្លាំងក្លានោះដែរ។ គឺវាខុសពីការប្រជុំនយោបាយ។ ជាទូទៅ ការប្រជុំនយោបាយនេះធ្វើឡើងរៀងរាល់ពីរសប្តាហ៍ម្តង និងទៅតាមកំរិតផ្សេងៗពីគ្នា។ សមាជិកបក្សប្រជុំគ្នាតាមក្រុមរបស់ពួកគេរៀងៗខ្លួន។ សមាជិកនៃសម្ព័ន្ធយុវជនកុំមុយនីស្ត និងអ្នកដែលមិនមែនជាសមាជិកនៃក្រុមទាំងពីរនេះ ក៏ប្រជុំតាមក្រុមរបស់គេរៀងៗខ្លួនដែរ។

រៀងរាល់ពេលប្រជុំទាំងនេះ ប្រធានអង្គប្រជុំចាប់ផ្តើមនិយាយជារួមអំពីស្ថានភាពនយោបាយជាតិ និងអន្តរជាតិ។ បន្ទាប់មក គាត់ធ្វើការបូកសរុបលើស្ថានភាពផ្ទៃក្នុងរបស់ក្រុមពាក់ព័ន្ធនីមួយៗ។ នៅក្នុងការបូកសរុបនេះ គាត់លើកឡើងពីចំនុចល្អ និងកង្វះខាត ដោយបង្ហាញអំពីមូលហេតុ និងដំណោះស្រាយនៃកង្វះខាតទាំងនេះ។ បន្ទាប់មក តាមវេនរៀងៗខ្លួន សមាជិកទាំងអស់ចាប់ផ្តើមធ្វើជីវទស្សន៍។ ប្រធានអង្គប្រជុំជាអ្នកធ្វើមុនគេ។ នៅពេលចុងបញ្ចប់នៃការធ្វើជីវទស្សន៍ ម្នាក់ៗត្រូវបានអញ្ជើញឱ្យចោទសំណួរទៅកាន់អ្នកធ្វើជីវទស្សន៍ ឬសុំឱ្យបំភ្លឺលើចំណុចដែលខ្លួនយល់ថាមិនសូវច្បាស់។ បន្ទាប់មកទៀត មានការប្រជុំកសាង។ នៅក្នុងការប្រជុំនេះ បើសិនជាចង់ អ្នកចូលរួមនីមួយៗអាចធ្វើការវាយតម្លៃលើគុណសម្បត្តិ និងកង្វះខាតរបស់សាមីជន ដើម្បីបន្ទាប់មក ផ្តល់ជាដំណោះស្រាយមួយចំនួនដែលសមីជនមានសិទ្ធទទួលយក ឬច្រានចោល។ បន្ទាប់ពីអ្នកចូលរួមទាំងអស់គ្នាបានបញ្ចេញយោបល់រួចហើយ សាមីជនត្រូវបង្ខំចិត្តទទួលយក ដោយអោនលំទោន នូវការសរសើរ និងការរិះគន់ ជាពិសេសការរិះគន់ ដែលគេហៅថាមតិកសាង។ ជាវិធាន គេត្រូវចៀសវាងពន្យល់ហេតុផលការពារខ្លួន ក្នុងករណីដែលយោបល់រិះគន់ជាការបរិហារកេរ្តិ៍ ឬការចោទប្រកាន់ដ៏ពិតៗ។

នៅទីបញ្ចប់ ប្រធានអង្គប្រជុំធ្វើសេចក្តីសង្ខេបខ្លីមួយលើចំណុចខ្លាំង និងចំណុចខ្សោយដែលស្រង់ចេញពីការប្រជុំ ព្រមទាំងអ្វីដែលត្រូវយកជាមេរៀន ដែលជាបទពិសោធន៍ដ៏មានសារៈសំខាន់សម្រាប់ការងារនៅថ្ងៃមុខ។

រាល់ពេលប្រជុំជីវទស្សន៍ ខ្ញុំរំពឹងទុកជាមុនថាគេនឹងរិះគន់ខ្ញុំលើពីរចំណុចដដែលៗ៖ ការអប់រំរបស់ខ្ញុំនៅបស្ចិមប្រទេស និងស្ថានភាពប្តីប្រពន្ធរបស់ខ្ញុំ (មានប្រពន្ធបារាំង)។ តែយូរៗទៅ ខ្ញុំស៊ាំនឹងការរិះគន់បែបនេះ ដូច្នេះបានន័យថាវាលែងធ្វើឱ្យខ្ញុំមានប្រតិកម្មទៀត។ ក្រៅពីនេះ មិត្តភក្តិខ្លះទៀសវាងមិនរិះគន់ខ្ញុំលើពីរចំណុចនេះ។ វាជារឿងធម្មតាពីព្រោះពួកគាត់ស្ថិតក្នុងស្ថានភាពដូចខ្ញុំដែរ។ ឧទាហរណ៍ដូចជា ជួន ប្រាសិទ្ធិ និង អ៊ុក សាគុណា។ ក៏ប៉ុន្តែទោះយ៉ាងនេះក្តី ក្នុងចិត្ត ខ្ញុំដឹងគុណពួកគាត់ចំពោះការយោគយល់ទាំងនេះ។

យើងរស់នៅក្នុងភាពភ័យខ្លាចធ្វើអ្វីខុស។ អ្នកធ្វេសប្រហែស ឬប្រព្រឹត្តឆ្គាំឆ្គងដោយប្រការណាមួយក្នុងការបំពេញភារកិច្ចរបស់ខ្លួន អាចនឹងមានរឿងធំ ពីព្រោះថាគេអាចបកស្រាយ ឬក៏ចាត់ទុកថាវាជាអំពើវិទ្ធង្សនា ឬទង្វើក្បត់។ ការរស់នៅក្នុងបរិយាកាសបែបនេះពិតជាពិបាកទ្រាំខ្លាំងណាស់។ ខ្ញុំមានអារម្មណ៍ថាការដែលខ្ញុំទទួលការអប់រំពីបស្ចិមប្រទេស និងរៀបអាពាហ៍ពិពាហ៍ជាមួយនារីបរទេស គឺជាឧបសគ្គមួយដែលមិនអាចឆ្លងកាត់បាន។ គេមិនដែលផ្តល់តម្លៃសមស្របណាមួយដល់កិច្ចប្រឹងប្រែងរបស់ខ្ញុំក្នុងការសម្របខ្លួនទៅនឹងសហគមន៍ និងរាល់ការលះបង់របស់ខ្ញុំឡើយ។ លទ្ធផលនៃរាល់ការងារដែលខ្ញុំបានប្រឹងប្រែងបំពេញ និងអ្វីដែលខ្ញុំព្យាយាមធ្វើ គ្មានអ្វីក្រៅពីការរិះគន់ និងការចំអកឡកលើយនោះទេ។ ពីដំបូង ខ្ញុំសង្ស័យ។ បន្ទាប់មកទៀត ខ្ញុំចាប់ផ្តើមអស់សង្ឃឹម។ ខ្ញុំទទួលអារម្មណ៍ធេងធោងមិនអាចទប់ទល់បាន នៅលើផ្លូវទាល់មួយដែលមិនអាចចេញរួច។ បើសិនជាពុំមានវត្តមានភរិយា និងកូនស្រីទាំងពីរដែលខ្ញុំត្រូវទទួលបន្ទុកទាំងស្រុងទេនោះ ខ្ញុំប្រហែលជាធ្វើអត្តឃាតបាត់ទៅហើយ។

ដោយមិនអាចទ្រាំទ្រនឹងការរិះគន់មិនចេះចប់ទៀតលែងបាន ថ្ងៃមួយ យើងបាន (អ៊ិន សុភាព និងខ្ញុំផ្ទាល់) សុំការអនុញ្ញាតពី អៀង សារី ដើម្បីទៅរស់នៅជនបទ។ យើងកាន់តែឈឺចាប់ថែមទៀតនៅពេលដែលគេឆ្លើយតបមកយើងថា នៅពេលណាដែលយើងទៅដល់ជនបទភ្លាម គេនឹងកម្ទេចយើងចោលភ្លាម។

មានរឿងកំប៉ិកកំប៉ុកមួយទៀតដែលគួរលើកយកមកនិទានដែរ។ ការិយាល័យរបស់យើងទាំងអស់នៅក្រសួង សុទ្ធតែមានបំពាក់ម៉ាស៊ីនត្រជាក់។ ក៏ប៉ុន្តែ គេហាមយើងមិនឱ្យប្រើប្រាស់វាទេ។ ទន្ទឹមនឹងនោះ ដើម្បីកុំឱ្យវាខូច យើងត្រូវបើកវា១៥នាទីម្ដងក្នុងមួយខែ។ ដោយខ្លាចគេចោទថាមាននិន្នាការអភិជន រាល់ពេលបើកម៉ាស៊ីនត្រជាក់ ខ្ញុំតែងតែប្រាប់មនុស្សទាំងអស់គ្នាជាមុនសិន មុននឹងបើកទ្វារ និងបង្អួចនៃការិយាល័យខ្ញុំចំហឱ្យធំៗ។

ការិយាល័យនេះស្ថិតនៅផ្នែកចុងខាងលិចបំផុតនៃអាគារធំរបស់ក្រសួង។ អ្នកដែលមកធ្វើការទាំងអស់ត្រូវដើរកាត់មុខការិយាល័យខ្ញុំ។ កម្មាភិបាលដែលមកពីខេត្តនានាចូលចិត្តមកជួបជុំគ្នាក្នុងការិយាល័យខ្ញុំជាមុនសិន មុននឹងចូលទៅការិយាល័យរបស់ពួកគេវិញ។ ពួកគាត់ស្ទើរតែទាំងអស់ជាគ្រូបង្រៀនសាលាបឋមសិក្សា និងសាស្ត្រាចារ្យ ដែលបានចូលព្រៃម៉ាគីក្នុងឆ្នាំ១៩៦៨ បន្ទាប់ពីមានការបះបោររបស់កសិករនៅស្រុកសំឡូត ខេត្តបាត់ដំបង។ ឯកអគ្គរដ្ឋទូតដំបូងៗនៃរបបកម្ពុជាប្រជាធិបតេយ្យសុទ្ធតែបានជ្រើសរើសចេញពីកម្មាភិបាលមូលដ្ឋានទាំងអស់នេះ។ ក្នុងចំណោមពួកគាត់មាន ស៊ឹម សុន ឯកអគ្គរដ្ឋទូតប្រចាំនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ពេជ្រជាង ឯកអគ្គរដ្ឋទូតប្រចាំនៅសាធារណរដ្ឋប្រជាមានិតចិន សម សាន ជាអ្នកបន្តតំណែងឯកអគ្គរដ្ឋទូតប្រចាំនៅកូរ៉េខាងជើងពី ស៊ឹម សុន អ្នកស្រី សូ សែ កម្មាភិបាលភូមិភាគបូព៌ា ត្រូវជាភរិយារបស់លោក ប៉េះ ប៊ុនរេត ដែលជាអ្នកតំណាងអចិន្ត្រៃយ៍របស់កម្ពុជាប្រជាធិបតេយ្យប្រចាំនៅគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចនៃទ្វីបអាស៊ី និងប៉ាស៊ីហ្វិច (ESCAP)។ លោកបានទទួលមរណភាពនៅទីក្រុងបាងកក កាលពីថ្ងៃទី២២ ខែមិនា ឆ្នាំ២000 ដោយជំងឺដាច់សសៃឈាមក្នុងខួរក្បាល។

អ្នកស្រី សូ សែ មានដើមកំណើតនៅស្រុកឆ្លូង ខេត្តក្រចេះ។ គាត់ជាអ្នកតំណាងភូមិភាគបូព៌ានៅសភាប្រជាជនឯទក្រុងភ្នំពេញ អ្នកស្រីកាន់តំណែងជាប្រធានលេខាធិការដ្ឋាន បន្ថែមពីលើតំណែងជាលេខានៃខុទ្ទកាល័យបក្សនៅក្រសួងតែមួយ។ ខ្ញុំជាអនុប្រធានផ្ទាល់បន្ទាប់ពីគាត់ ទាំងនៅលេខាធិការដ្ឋាន ទាំងនៅនាយកដ្ឋានពិធីសារដែលគាត់ជាប្រធានមុនពេលដែល នី កន មកដល់។ ផ្ទះកំណើតរបស់គាត់ស្ថិតនៅចំពីក្រោយផ្ទះខ្ញុំ កាលដែលខ្ញុំនៅរៀនសាលាបឋមសិក្សាបំពេញវិជ្ជាឆ្លូងពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៥០។ ខ្ញុំបានដឹងថាគាត់មកពីណា ដោយសារតែការសន្ទនាគ្នាដោយចៃដន្យមួយក្នុងឆ្នាំ១៩៨២ នៅទីក្រុងបាងកក ដែលគាត់ធ្វើការជាអ្នកតំណាងអចិន្ត្រៃយ៍រង របស់កម្ពុជាប្រជាធិបតេយ្យប្រចាំនៅ ESCAP។ នៅពេលនោះ គាត់បានប្រាប់ខ្ញុំថាគាត់ស្គាល់ តឹក អង្គរី ដែលជាមិត្តរួមថ្នាក់ខ្ញុំនៅឆ្លូង និងថាផ្ទះរបស់ តឹក អង្គរីនេះ នៅជាប់នឹងផ្ទះគាត់។ កាលពីសម័យដែល

គាត់ធ្វើការនៅក្រសួង ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ គាត់បាននិយាយប្រាប់ខ្ញុំថាគាត់កើតនៅតំបន់ដំរីផុង ដែលស្ថិតនៅខាងត្បូងឆ្ងូង។ គាត់អាចលាក់អាថ៌កំបាំងអំពីដើមកំណើតរបស់គាត់ជាច្រើនឆ្នាំ ស្របតាមពាក្យស្លោកពេញនិយមនាសម័យនោះដែលថា៖ "រក្សាការសម្ងាត់បាន គឺឈ្នះ ៥០ ភាគរយជាស្រេច"។

ស៊ឹម សុន ហៅ យ៉ែម ក៏មកពីតំបន់ស្វយ័ត (៥០៥) នៃខេត្តក្រចេះដែរ។ នៅទីនោះ ភរិយាខ្ញុំឈ្មោះ តាំង ហ៊ុយអេង ធ្វើការជាអ្នកទទួលខុសត្រូវផ្នែកសេដ្ឋកិច្ច។ សម័យនោះ ស៊ឹម សុន តំណាងឱ្យកម្មាភិបាលគំរូ ដូចដែលកម្ពុជាប្រជាធិបតេយ្យចង់បាន ពោលគឺគាត់ស្មោះត្រង់ មានស្មារតីលះបង់អំណាត់អត់ធន និងផ្សារភ្ជាប់ខ្លួនយ៉ាងស្និទ្ធស្នាលជាមួយមហាជន។ ប្រពន្ធគាត់ជាសាច់ថ្លៃរបស់ កុយ ធួន ដែលជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជាប្រជាធិបតេយ្យ ជាអតីតអ្នកដឹកនាំភូមិភាគឧត្តរ និងត្រូវបានគេកម្ទេចនៅឆ្នាំ១៩៧៧ ក្រោមបទចោទប្រកាន់ថាប៉ុនប៉ងធ្វើរដ្ឋប្រហារទម្លាក់ ប៉ុល ពត។ ជាអតីតគ្រូបង្រៀនសាលាបឋមសិក្សា យ៉ែមចូលចិត្តសូត្រពាក្យកាព្យរបស់លោក ឡាហ្វុងតែន ជាពិសេសរឿងល្បើក "ចចកនិងកូនចៀម" និង "រៃនិងស្រមោច" ព្រមទាំងសុភាសិត "កុំបំបាត់ធម្មជាតិ ពីព្រោះវានឹងត្រឡប់មកវិញយ៉ាងលឿន"។

ស៊ឹម សុន បានបញ្ចប់ជីវិតរបស់គាត់ដោយសោកសៅ នៅឆ្នាំ១៩៩០។ នៅស្ថានទូតខ្មែរប្រចាំនៅទីក្រុងប៉េកាំង ខ្ញុំកំពុងតែអានកំណាត់អត្ថបទកាសែតថៃ ដែលបេសកកម្មអចិន្ត្រៃយ៍របស់យើងប្រចាំនៅ ESCAP នាទីក្រុងបាងកក បានផ្ញើមកយើង។ អារម្មណ៍របស់ខ្ញុំកំពុងតែផ្តោតទៅលើអត្ថបទកាសែតសរសេរជាភាសាអង់គ្លេស "THE NATION" ដែលមានចំណងជើងថា៖ "លោក អៀង សារី លេចមុខឡើងវិញជាសាធារណៈ"។ គឺនៅក្នុងឱកាសនៃពិធីបូជាសាកសពរបស់លោក ស៊ឹម សុន នៅវត្តថៃ ឈ្មោះ នុង ព្រុយ ដែលស្ថិតនៅទល់មុខស្រុកម៉ាឡៃ។ គាត់បានស្លាប់កាលពីបីថ្ងៃមុននេះ ដោយត្រូវដើមឈើពុកបាក់សង្កត់លើ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩០ ក្នុងខណៈដែលគាត់ចុះពីលើផ្ទះគាត់ដើម្បីទៅស្រស់ស្រូបអាហារថ្ងៃត្រង់។

ការស្លាប់មុនអាយុរបស់គាត់ធ្វើឱ្យមនុស្សគ្រប់រូបឈឺចាប់យ៉ាងខ្លាំង ដោយសារគាត់ជាមនុស្សសាមញ្ញ ស្លូតបូត និងកិច្ចប្រឹងប្រែងរបស់គាត់ដើម្បីបំរើសហគមន៍។ ក្រោយពីបានទទួលដំណឹងដ៏ក្រៀមក្រំនេះ ភរិយាខ្ញុំដែលធ្លាប់ធ្វើការក្រោមការដឹកនាំរបស់គាត់នៅខេត្តក្រចេះ បានយំសោកសង្រេងយ៉ាងខ្លាំង ពីព្រោះគាត់ស្រលាញ់រាប់អានគាត់និងក្រុមគ្រួសារគាត់យ៉ាងជ្រៀលជ្រៅ។

ដំណើរជីវិតខ្ញុំនៅមន្ទីរ ប១ ប្រព្រឹត្តទៅនៅក្នុងភាពស្រពេចស្រពិលលាយឡំនឹងការភ័យខ្លាច។ គឺភាពស្រពេចស្រពិលអំពីថ្ងៃស្អែកដែលធ្វើឱ្យខ្ញុំមានអារម្មណ៍ថា ខ្លួនស្ថិតនៅក្នុងភាពទាល់ច្រក ខណៈដែល "បដិវត្តន៍សង្គមនិយម" ដើរទៅមុខកាន់តែលឿនទៅៗ។ ការភ័យខ្លាច គឺភ័យខ្លាចខ្លួនពុំមានប្រយោជន៍អ្វីទាល់តែសោះចំពោះសមូហភាព ជាពិសេសភ័យខ្លាចអំពីម្ដាយរបស់កូនស្រីទាំងពីររបស់ខ្ញុំ ពីព្រោះខ្ញុំគិតទុកជាមុនរួចស្រេចទៅហើយថាគេនឹងមកចាប់គាត់ ដោយចោទថាគាត់ជាគេញរបស់ភ្នាក់ងារសម្ងាត់បារាំង SDECE។

ចំពោះខ្ញុំវិញ ខ្ញុំនឹងយល់ព្រមទទួលយកដោយស្ម័គ្រចិត្តនូវរាល់ការចោទប្រកាន់មកលើខ្ញុំពីបទអ្វីមួយក៏បានដែរ ពីព្រោះខ្ញុំធ្លាក់ដល់ថ្នាក់ជឿជាក់ថាគោលជំហរមនោគមវិជ្ជារបស់ខ្លួនប្រហែលជាមិនសូវរឹងមាំ ដែលអាចបណ្ដាលឱ្យគេរកឃើញចំនុចអវិជ្ជមានរបស់ខ្ញុំ និងដែលអាចឱ្យគេដឹងជាយថាហេតុថាទង្វើរបស់ខ្ញុំស្រប ឬមិនស្របតាមមាគ៌ាបក្ស។ ខ្ញុំស្ថិតក្នុងស្ថានភាពដូចគ្នានឹងសមាជិកនៃគណៈមជ្ឈិមម្នាក់ដែលគេត្រៀមប្រហារជីវិត ហើយមុននឹងដួលស្លាប់ក្រោមគ្រាប់កាំភ្លើងពេជ្ឈឃាដ គាត់បានស្រែកថា ៖ "ជយោបក្សកុំមុយនីស្ដកម្ពុជា! ជយោសមមិត្ត ប៉ុល ពត!" ទោះបីជា ប៉ុល ពត នេះ ជាអ្នកបញ្ជាឱ្យគេប្រហារជីវិតគាត់ក៏ដោយ។

ការដែលធ្វើឱ្យគេទទួលខ្លួនជាសមាជិកបក្ស និងធ្វើឱ្យថ្នាក់ដឹកនាំមើលឃើញភក្ដីភាពមិនចេះប្រែប្រួល និងការលះបង់ចំពោះមុខរាល់ការលំបាករបស់ខ្លួន ទាំងនេះសុទ្ធតែជាបំណងប្រាថ្នាកំពូលបំផុតរបស់មនុស្សគ្រប់រូប។ បក្សមានអំណាចខ្លាំងបំផុត។ បក្សមិនចេះច្រឡំ ត្រឹមត្រូវ និងយុត្តិធម៌។ តាមបែបណាមួយនោះ បក្សជាអាទិទេពថ្មីមួយ។ ការចោទប្រកាន់បក្សគឺជាការប្រមាថអាទិទេព។ ឧត្ដមភាពរបស់បក្សលើគ្រប់ទិដ្ឋភាពទាំងអស់ក្នុងជីវិតប្រចាំថ្ងៃ មិនមែនរួមចំណែកដ៏ធំធេងក្នុងការដុះខាត់មនសិការវណ្ណៈ ដូចដែល ប៉ុល ពតចង់បាននោះទេ ប៉ុន្តែវារួមចំណែកក្នុងការធ្វើឱ្យខ្មែរមិនទុកចិត្តគ្នា និងស្អប់គ្នាទៅវិញទេ។ ក្នុងន័យនេះ ទស្សនៈប៉ុលពតនិយម គឺជាកាតាលិករនៃការបំបែកបំបាក់ និងការស្អប់ខ្ពើម។ ប៉ុល ពត ចូលចិត្តប្រៀបធៀបសមាជិកបក្សដែលខ្លួនផ្ដល់តម្លៃស្មើនឹងមាសទឹកដប់ ទៅនឹងសមាសភាពផ្សេងៗទៀតនៃសង្គម ដែលគាត់ចាត់ទុកដូចជា "ភក់ជ្រាំ និងលាមក"។

**៧) នៅសាលារៀនរបស់បក្ស**

ជាសមាជិកបក្សពេញសិទ្ធតាំងពីខែកុម្ភៈឆ្នាំ១៩៧១ ខ្ញុំត្រូវបានទទួលឱ្យចូលរួមសិក្ខាសាលាប្រចាំឆ្នាំរបស់បក្សរយៈពេលពីរសប្តាហ៍ នៅពហុកីឡដ្ឋានជាតិភ្នំពេញ ក្នុងខែមិថុនាឆ្នាំ១៩៧៦។ ការជ្រើសរើសនេះ គឺជាការផ្តល់កិត្តយសដល់ខ្ញុំ ហើយខ្ញុំស្តាប់វាគ្មិនសំខាន់ទាំងពីរអ្នក ពោរពេញទៅដោយការស្ញើចសរសើរ។ វាគ្មិនទាំងពីនេះពុំមាននរណាក្រៅពី ប៉ុល ពត និង នួន ជា ទេ។

សិក្ខាសាលានេះមានទិសដៅបំពាក់បំប៉ន និងពង្រឹងគោលជំហរនយោបាយ និងមនោគមវិជ្ជារបស់សមាជិកបក្ស។ សិក្ខាសាលាចែកចេញជាពីរផ្នែក។ ផ្នែកទីមួយគឺជាវគ្គបំពាក់បំប៉ននយោបាយ និងមនោគមវិជ្ជា ដែល ប៉ុល ពត និង នួន ជា ធ្វើបទបង្ហាញដោយខ្លួនឯងផ្ទាល់។ ផ្នែកទីពីរគឺជាវគ្គឆ្លងជីវទស្សន៍ ដោយមានម៉ោងបង្ហាញរបៀបធ្វើជាមុន។

គឺនៅពេលចូលរួមសិក្ខាសិលានេះហើយដែលខ្ញុំបានស្គាល់ លោក សំ ឌី ប្រធានតំបន់៣២ ដែលក្រោយមក នៅខែមករា ឆ្នាំ១៩៧៩ បានជួយខ្ញុំឱ្យទៅដល់ប៉ុស្តិ៍បញ្ជាការរបស់លោក ប៉ាល់ ដែលជាប្រធានគណៈភូមិភាគបស្ចិម នៅឃុំត្រពាំងជោរ នៅភ្នំឱរ៉ាល់។ ខ្ញុំក៏បានភ្ជាប់ទំនាក់ទំនងជាមួយ លី គួយ ដែលជាប្អូនថ្លៃប្រុសរបស់ នួន ជា ដែលប្រពន្ធគាត់ជាមិត្តភក្តិរបស់ប្រពន្ធខ្ញុំ។ គួយជាប្រធានមន្ទីរ (ជាប្រភេទនាយកដ្ឋានបុគ្គលិកមួយ) នៃក្រសួងព័ត៌មានដែលពីមុនមាន អ្នកស្រី យន់ យ៉ាត ត្រូវជាភរិយា សុន សេន ជាប្រធាន។ គួយ ដែលតំណាងឱ្យភាគី នួន ជា នៅក្នុងថ្នាក់ដឹកនាំខ្មែរក្រហមត្រូវប្រឈមមុខជាច្រើនដងជាមួយនឹង យន់ យ៉ាត។ ការណ៍នេះជាមូលហេតុនៃការដក យន់ យ៉ាត ចេញពីតំណែង នៅខែធ្នូឆ្នាំ១៩៧៨។

នៅខែកញ្ញាឆ្នាំ១៩៩៣ បន្ទាប់ពីខ្មែរក្រហមបាក់ទ័ពនៅភ្នំឆ័ត្រដែលស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា គួយ និងក្រុមគ្រួសាររបស់គាត់បានមកស្នាក់នៅផ្ទះខ្ញុំ នៅម៉ាឡៃពីរបីថ្ងៃ មុននឹងទៅអន្លង់វែង។ ខ្ញុំបានជួបគាត់ជាថ្មីម្តងទៀតនៅឆ្នាំ១៩៩៨ បន្ទាប់ពីចលនាខ្មែរក្រហមបានបែកខ្ញាត់ខ្ញាយ។

គួយ និងស៊ឹម សុន តំណាងឲបញ្ញាវន្តគំរូដែលបានទទួលការបណ្តុះបណ្តាលក្នុងស្រុក។ ជាសាស្ត្រាចារ្យនៅវិទ្យាល័យ គួយប្រាកដជាបានចូលព្រៃម៉ាគីយ៉ាងឆាប់រហ័ស ដើម្បីចូលរួមក្នុងការតស៊ូប្រដាប់អាវុធ។ គាត់រស់នៅ និងធ្វើការងារដូចជាប្រជាពលរដ្ឋសាមញ្ញ ហើយថែមទាំងបូជាកម្លាំងកាយចិត្តដើម្បីសហគមន៍ ដោយមិនគិតពីសុខភាពផ្ទាល់ខ្លួន។ ប៉ុន្តែគាត់ចេះបង្ហាញនូវភាពបត់បែនយ៉ាងរហ័សទៅតាមដំណើរវិវត្តឡើងចុះយ៉ាងគំហុកនៃស្ថានភាពនយោបាយ។

ដោយដឹងខ្លួនថាបានរស់នៅបរទេសយូរពេក ក្នុងខណៈដែលប្រជាជន និងកម្មាភិបាលលះបង់កម្លាំងកាយចិត្តដើម្បីបុព្វហេតុបដិវត្តន៍ ខ្ញុំបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយអ្នកតំណាងភូមិភាគនានាក្នុងប្រទេស ទៅតាមដែលអាចធ្វើបាន។ ជាការតបស្នងមកខ្ញុំវិញ ពួកគាត់ផ្តល់នូវទំនុកចិត្ត និងមិត្តភាពចំពោះខ្ញុំ។

## ៨) ការភ្ញាក់ខ្លួនដំបូង

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ភាពជាបញ្ញាជន ជាពិសេសបញ្ញាជនដែលបានទទួលការបណ្តុះបណ្តាលពីបស្ចិមប្រទេស គឺជាគុណវិបត្តិមួយដែលស្ទើរតែចៀសមិនរួច។ បញ្ញាជននៃមន្ទីរ ប១ ក៏មិនគេចផុតពីច្បាប់នេះដែរ បើទោះបីជាពួកយើងម្នាក់ៗខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីបំពេញការងារដែលគេកំណត់ឱ្យធ្វើក៏ដោយ។ ម្នាក់ៗប្រជែងគ្នាយ៉ាងក្លៀវក្លា ប្រកបដោយការព្យាយាម និងពលីកម្ម សំដៅរួមចំណែកក្នុងបុព្វហេតុកសាងជាតិ។ ទោះបីជាមានការបំបាត់ និងរឹតត្បិតសេរីភាពរបស់យើងក៏ដោយ ក៏យើងខំប្រឹងប្រែងទ្វេដង ដើម្បីឱ្យបក្សទុកចិត្ត និងស្ញើចសរសើរ។ យើងមិនដែលនឹកគិតដល់ការសង្ស័យម្តងណាសោះឡើយ។ ការសួរនាំទាក់ទងនឹងមាគ៌ា និងសមិទ្ធផលរបស់បក្ស មានទោសស្មើនឹងអំពើក្បត់។ នេះគឺជាទំរង់ថ្មីមួយនៃទស្សនៈជ្រុលនិយមដែលផ្ទុយទៅនឹងការអនុគ្រោះ ស្មារតីទិតៀន និងសត្យានុម័តិ។ គេមិនត្រូវមានសតិអារម្មណ៍ចំពោះបក្ស និងការដឹកនាំរបស់បក្សឡើយ ទោះបីជានៅកំរិតណាក៏ដោយ។ គឺស្មារតីនេះហើយដែលបណ្តាលឱ្យមានការធ្វើបាប និងការបំពារបំពានច្រើនដល់ម្លឹង ព្រមទាំងបណ្តាលឱ្យមានឧក្រិដ្ឋកម្មជាទ្រង់ទ្រាយច្បាស់ថែមទៀតផង។ ទំនួលខុសត្រូវរបស់មេដឹកនាំខ្មែរក្រហមស្ថិតនៅត្រង់ចំណុចនេះឯង។

ទោះជាយ៉ាងណាក្តី ការមន្ទិលសង្ស័យ និងការមិនសូវជឿបានចាប់ផ្តើមលេចឡើង។

មុនដំបូង គឺការសង្ស័យ។ ក្រោយថ្ងៃជ័យជំនះខែមេសា ឆ្នាំ១៩៧៥ រដ្ឋាភិបាលថ្មីបានផ្សព្វផ្សាយពាក្យស្លោកថា ប្រជាជនកម្ពុជានឹងកើនឡើងទ្វេដងក្នុងរយៈពេលដប់ឆ្នាំ។ ខ្ញុំដឹងច្បាស់ណាស់ថាកំណើនចំនួនប្រជាជនទ្វេដងនៅក្នុងប្រទេសមួយដែលមានកំណើនប្រជាជនមធ្យម ត្រូវការរយៈពេលយ៉ាងតិចម្ភៃឆ្នាំ។ ដូច្នេះ ប្រទេសកម្ពុជាមិនអាចបង្កើនចំនួនប្រជាជនពីប្រាំពីរលាននាក់ទៅដប់ប្រាំលាននាក់បានទេ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៨៥។

បន្ទាប់មកទៀត គឺការមិនសូវជឿ។ រដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យបានកំណត់ទិន្នផលស្រូវបីតោនមួយហិចតាក្នុងមួយឆ្នាំ។ ប៉ុន្តែខ្ញុំពុំឃើញមានអ្វីដែលអាចជាកត្តាជំរុញឱ្យទិន្នផលកើនឡើងមួយជាបីឡើយ ពីព្រោះថានៅចន្លោះឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ ទិន្នផលស្រូវមធ្យមសឹងតែមិនលើសពីមួយតោនផងក្នុងមួយហិចតា។

បន្តិចក្រោយមក ការមិនសូវជឿបានឈានចូលដល់ការលែងជឿតែម្តង ពោលគឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ក្នុងពិធីប្រារព្ធខួបលើកទីបីនៃជ័យជំនះ ក្នុងខណៈដែល ប៉ុល ពត បានប្រកាសថាយោធាខ្មែរតែម្នាក់អាចផ្តួលយោធាវៀតណាមបានសាមសិបនាក់ ហើយថាបើសិនយើងលះបង់អ្នកស្នេហាជាតិចំនួនពីរលាននាក់ យើងប្រហែលជាអាចកម្ទេចប្រជាជនវៀតណាមឲ្យសាបសូន្យទាំងអស់បាន។ វាគ្មានន័យអ្វីក្រៅពីការធ្វើឱ្យភ្ញាក់ផ្អើលនោះទេ។ ប៉ុន្តែសេចក្តីប្រកាសនេះពិតជាចេញពីមាត់ផ្ទាល់របស់ ប៉ុល ពត។

ចម្ងាយពីការលែងជឿទៅការលើកយកមកចោទជាបញ្ហា គ្រាន់តែឈានមួយជំហានដល់បាត់ទៅហើយ។

ឧប្បត្តិហេតុមួយដែលបានផ្ទុះឡើងនៅខែមិនា ឆ្នាំ១៩៧៧ លើកំណាត់ផ្លូវជាតិលេខ៦ ដែលតភ្ជាប់ពីខេត្តសៀមរាប ទៅស្រុកសេរីសោភ័ណ បានធ្វើឱ្យខ្ញុំមានចម្ងល់ជាច្រើន។ កាលនោះ នី កន ប៉េះប៊ុនរ៉េត និងខ្លួនខ្ញុំផ្ទាល់ ពួកយើងបានអមដំណើរឯកអគ្គរដ្ឋទូតស៊ុយអែតប្រចាំនៅប្រទេសថៃ និងភរិយារបស់គាត់ដែលចង់ទៅទស្សនាប្រាសាទអង្គរម្តងទៀត ហើយជាពិសេសចង់គយគន់ថ្ងៃអស្តង្គតនៅលើប្រាសាទបាក់បែកល្បីៗ។ នៅពេលត្រឡប់ទៅប៉ោយប៉ែតដែលជាក្រុងមួយនៅជាប់នឹងព្រំដែនថៃ ឡានយើងក៏ខូចតាមផ្លូវ។ នៅពេលយើងកំពុងតែរវល់ជួសជុលឡាន កុមារីម្នាក់អាយុ១២ឆ្នាំមកនិយាយរកយើង ហើយសុំឱ្យយើងយកនាងមកនៅភ្នំពេញ។ ដើម្បីបញ្ចុះបញ្ចូលយើង នាងចាប់ផ្តើមរៀបរាប់អំពីការរស់នៅរបស់នាង ក្នុងសហករណ៍មួយនៃស្រុកភ្នំស្រុក ក្នុងខេត្តបាត់ដំបង ក្នុងគ្រានោះ។ ដោយទទួលរបបបបររាវមួយស្លាបព្រាក្នុងមួយពេល និងដោយត្រូវធ្វើការដ៏លំបាក នាងស្ទើរតែមិនអាចបន្តរស់ក្នុងសហករណ៍នោះទៀតបាន។ នាងមិនអាចនិយាយកុហកយើងបានទេ ពីព្រោះថារាងកាយនាងបង្ហាញពីភាពកង្វះអាហារដ៏ធ្ងន់ និងការធ្វើការហួសកម្លាំងច្រើន។ ខ្ញុំក៏ចោទសួរខ្លួនឯងថាហេតុដូចម្តេចបានជានៅតំបន់មួយដែលល្បីថាជាជង្រុកស្រូវនៃប្រទេសកម្ពុជា មនុស្សបែរជាធ្លាក់ដល់ថ្នាក់ហូបបបររាវទៅវិញ?

មានរឿងមួយទៀតដែលធ្វើឱ្យខ្ញុំសង្ស័យលើសេចក្តីប្រកាសផ្លូវការដែលថា ស្ថានភាពក្នុងស្រុកកាន់តែប្រសើរឡើងជាលំដាប់។ កាលនោះ គឺនៅពាក់កណ្តាលឆ្នាំ១៩៧៨។ នៅក្រសួង យើងខ្វះកម្មាភិបាលមានសមត្ថភាព។ ខ្ញុំក៏សុំ អៀង សារី ឲ្យហៅបញ្ញាជនមួយចំនួនដែលខ្ញុំស្គាល់ច្បាស់ទាំងគុណសម្បត្តិសីលធម៌ ទាំងសមត្ថភាពវិជ្ជាជីវៈ។ កម្មាភិបាលទាំងនោះរួមមាន ទាវ ជិនឡេង ជាមិត្តភក្តិម្នាក់ក្នុងចំណោមមិត្តភក្តិជិតស្និតបំផុតរបស់ខ្ញុំ ជាវិស្វករខាងស្ពាន និងផ្លូវថ្នល់ ជាអតីតប្រធានកំពង់ផែទីក្រុងព្រះសីហនុ ខួន ដារីដ ជាបណ្ឌិតផ្នែកវិទ្យាសាស្ត្រគណិតវិទ្យាមកពីសាកលវិទ្យាល័យប៉ារីស និង យ៉ែម រ៉ុម ជាអនុបណ្ឌិតផ្នែករូបវិទ្យាមកពីសាកលវិទ្យាល័យប៉ារីស។ ទាវ ជិនឡេង បានទុកភរិយាបារាំង និងកូនប្រុសអាយុបីឆ្នាំរបស់គាត់ចោល ដើម្បីត្រឡប់មកប្រទេសវិញ ភ្លាម ក្រោយថ្ងៃរំដោះ។ ប៉ុន្តែ បន្ទាប់ពីស្វែងរកពួកគាត់អស់រយៈពេលជាច្រើនសប្តាហ៍មិនឃើញ យើងក៏សន្និដ្ឋានថាពួកគាត់បាត់ខ្លួន។ ចាប់ពីពេលនោះមក យើងមិនដែលឮគេនិយាយអំពីពួកគាត់ទេ។

ស្បែបិទមុខចាប់ផ្តើមរបើក ហើយនៅពីក្រោយការអះអាងជាផ្លូវការអំពីជ័យជំនះ ព្រឹត្តិការដ៏ធ្ងន់បានកើតឡើង។ ប៉ុន្តែគេបំបិទមិនឱ្យយើងដឹងអំពីព្រឹត្តការទាំងនេះសោះតែម្តង។ បើសិនជាយើងចង់ដឹងច្រើន យើងនឹងប្រឈមមុខនឹងការដែលគេគិតថាយើងមានមន្ទិលសង្ស័យ។ បើយើងទទូចចង់ដឹង យើងអាចរងគ្រោះពីការចោទប្រកាន់ធ្ងន់ជាងហ្នឹងទៅទៀត។ ដូច្នេះ អ្វីដែលប្រសើរជាងគេ គឺបិទភ្នែក និងចុកត្រចៀក។ ប៉ុន្តែវាប្រឆាំងនឹងចរិតផ្ទាល់ខ្លួនរបស់យើង។ គេមិនឱ្យយើងដឹងអ្វីទាំងអស់ សូម្បីតែរឿងដែលទាក់ទងនឹងយើងដោយផ្ទាល់ក៏គេមិនឱ្យយើងដឹងដែរ។

កាលពីដំបូង យើងព្រមទទួលរបៀបដឹកនាំចម្លែកនេះ ដោយមូលហេតុគោរពវិន័យច្រើនជាងដោយមូលហេតុមានជំនឿជឿជាក់។ ប៉ុន្តែ នៅពេលដែលទឹករងបន្តិចម្តងៗ ហើយយើងអាចឃើញថាតើត្រីវិវត្តយ៉ាងណានោះ ចរិតពិតរបស់យើងដែលស្រេកឃ្លានការពិត និងសមធម៌បានត្រឡប់មកគ្របដណ្តប់យើងវិញ។ ជាការពិត វាជាការវិវត្តយឺតៗ ប៉ុន្តែការវិវត្តនេះប្រព្រឹត្តទៅដោយមិនត្រឡប់ក្រោយ។ ពីជនជ្រុលនិយម ពីអ្នកប្រកាន់កុំមុនីស្តដ៏ងប់ងុល យើងប្រែមកជាអ្នកគាំទ្រលទ្ធិប្រជាធិបតេយ្យសង្គមច្រើនជាង។

VII. **១៩៧៩ ÷ ឆ្នាំដ៏រន្ធត់**

*[អានមិនដាច់]*